## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស

## ក្រសួងសុខាភិបាល

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស

ថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០២១

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ឈ្លាសវៃ និងម៉ឺងម៉ាត់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានបង្ហាញនូវសមត្ថភាពនិងឆន្ទៈដ៏មុតស្រួចក្នុងការឆ្លើយតបតាមគ្រប់មធ្យោបាយដើម្បីបង្ការ និងគ្រប់គ្រងការចម្លងរាតត្បាតក្នុងសហគមន៍នៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា តាមរយៈអភិក្រមប្រព័ន្ធទាំងមូល រដ្ឋាភិបាលទាំងមូល និងសហគមន៍ទាំងមូល។

ការរកឃើញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បានផ្តល់នូវពន្លឺនៃសេចក្តីសង្ឃឹមប្រកបដោយទំនុកចិត្តមួយថ្មីទៀតក្នុងការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ដ៏កាចសាហាវនេះ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ដល់ប្រជាពលរដ្ឋគោលដៅអាទិភាព តាមគោលការណ៍ស្ម័គ្រចិត្ត និងមិនបង់ថ្លៃ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ខណៈដែលវ៉ាក់សាំងកូវីដ-១៩ ក្នុងបរិមាណច្រើនទៀត ត្រូវបានរំពឹងនឹងមកដល់ប្រទេសកម្ពុជា ជាបន្តបន្ទាប់នៅក្នុងអំឡុងពេលខាងមុខ។ អាស្រ័យហេតុនេះ «ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស» ត្រូវបានរៀបចំឡើង ដើម្បីបំពេញបន្ថែមនូវគោលការណ៍ និតិវិធី យុទ្ធសាស្ត្រ និងសកម្មភាព ដើម្បីជំរុញការងារចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានទាន់ពេលវេលា មានសុវត្ថិភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ផែនការមេនេះត្រូវបានរៀបចំឡើង ដោយផ្អែកមូលដ្ឋានគ្រឹះនៃ «ផែនការជាតិស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩» ដែលក្រសួងសុខាភិបាលបានដាក់ចេញ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។ គោលដៅប្រកបដោយមហិច្ឆតាដែលបានកំណត់នៅក្នុងផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស គឺការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋគោលដៅឱ្យបាន ១០លាននាក់ នៅពាក់កណ្តាលឆ្នាំ២០២២។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ ឯ.ឧ វេជ្ជបណ្ឌិត ឡូ វ៉ាសនាគីរី រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាអនុប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ដែលបានដឹកនាំអនុគណៈកម្មការចំពោះកិច្ចផែនការ និងថវិកានីយកម្ម ក្នុងការអភិវឌ្ឍផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងសូមអរគុណចំពោះ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត អង្គការសុខភាពពិភពលោក និងអង្គការយូនីសេហ្វ ដែលបានផ្តល់ជាតុចូលដល់ការកសាងផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។

ខ្ញុំសង្ឃឹមថា ការអនុវត្តយ៉ាងសកម្មនូវផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ផ្សារភ្ជាប់ជាមួយការអនុវត្តវិធានការ «៣ កុំ និង ៣ ការពារ» និងការពង្រឹងប្រព័ន្ធសន្តិសុខសុខភាពជាតិ នឹងផ្តល់ឱកាសឱ្យប្រទេសកម្ពុជាយើងទទួលបានជោគជ័យក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។

ថ្ងៃ ពុធ ៣ រោច ខែ ចេត្រ ឆ្នាំ ជូតទោស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ៣១ មីនា ឆ្នាំ ២០២១
**រដ្ឋលេខាធិការ និងជាប្រធានគ.វ.ក-១៩**

វេជ្ជ. ឱ្យ_វណ្ណឌីន

# មាតិកា

1 **សេចក្តីផ្តើម** ..... 1

1.1 សន្និទានកម្ម ..... 1

1.2 គោលបំណង ..... 2

1.3 គោលដៅ ..... 2

1.4 គោលការណ៍នៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 2

1.5 យុទ្ធសាស្ត្រនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 3

2 **អតិក្រមនៃការចាក់វ៉ាក់សាំង** ..... 4

2.1 ដំណាក់កាលនៃយុទ្ធនាការចាក់វ៉ាក់សាំង និងប្រជាពលរដ្ឋគោលដៅ ..... 4

2.2 យន្តការនៃការចាក់វ៉ាក់សាំង ..... 5

2.3 កិច្ចដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 5

2.3.1 ការចុះឈ្មោះចាក់វ៉ាក់សាំងទុកជាមុន ..... 5

2.3.2 ការរៀបចំទីកន្លែងសម្រាប់កិច្ចដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 6

2.3.3 ក្រុមការងារចាក់វ៉ាក់សាំង ..... 6

2.4 សមត្ថភាពនៃការចាក់វ៉ាក់សាំង ..... 8

3 **ការដឹកនាំ គ្រប់គ្រង ផែនការ និងសម្របសម្រួល** ..... 9

3.1 ពង្រឹងការដឹកនាំ និងគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ..... 9

3.2 កសាងផែនការសកម្មភាពសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 10

3.3 លើកកម្ពស់ការអនុវត្តផែនការ និងតាមដានត្រួតពិនិត្យការអនុវត្តផែនការ ..... 10

3.4 លើកកម្ពស់ការសម្របសម្រួលទូលំទូលាយក្នុងយុទ្ធនាការចាក់វ៉ាក់សាំង ..... 10

4 **ធនធានមនុស្ស** ..... 11

4.1 រៀបចំផែនការតម្រូវការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 11

4.2 បណ្តុះបណ្តាលធនធានមនុស្សយោងតាមតម្រូវការនៃផែនការបណ្តុះបណ្តាល ..... 12

4.3 បណ្តុះបណ្តាលបំប៉នផ្នែកគ្លីនិក ស្តីពីការគ្រប់គ្រងផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 13

4.4 ត្រួតពិនិត្យតាមដាន និងអភិបាលការប្រតិបត្តិគោលការណ៍ណែនាំឬពិធីសារនៃការងារចាក់វ៉ាក់សាំង ..... 13

5 ការគ្រប់គ្រងវ៉ាក់សាំង និងគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 14
5.1 លើកកម្ពស់ការងារគ្រប់គ្រង និងបែងចែក និងផ្គត់ផ្គង់វ៉ាក់សាំង/សម្ភារៈបរិក្ខារ ..... 14
5.2 ពង្រឹងការគ្រប់គ្រងប្រព័ន្ធត្រជាក់ថែរក្សាសុវត្ថិភាពនិងប្រសិទ្ធភាពវ៉ាក់សាំង ..... 15
5.3 គ្រប់គ្រងបញ្ជីសារពើភណ្ឌវ៉ាក់សាំង ..... 16
5.4 គ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងដើម្បីបង្ការការឆ្លងរោគ សុវត្ថិភាពនិងរក្សាអនាម័យបរិស្ថានល្អ..... 16
6 ការប្រាស្រ័យទាក់ទងនិងការចូលរួមរបស់សហគមន៍ ..... 18
6.1 លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋចូលរួមចាក់វ៉ាក់សាំងកូវីដ-១៩ ..... 19
6.2 ដាក់ឱ្យដំណើរការយន្តគ្រប់គ្រងផលរំខានក្រោយពីចាក់វ៉ាក់សាំងកូវីដ-១៩ និងក្រុមការងារស្រាវជ្រាវនៃផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ..... 20
6.3 លើកកម្ពស់ការយល់ដឹងរបស់គ្រូពេទ្យនិងបុគ្គលិកសុខាភិបាលអំពីអត្ថប្រយោជន៍ សុវត្ថិភាព និងផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩..... 21
6.4 ពង្រឹងយន្តការដែលមានស្រាប់នៅក្នុងសហគមន៍ ដើម្បីគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 21
7 ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ..... 22
7.1 អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យ/ព័ត៌មានទាក់ទងនឹងការងារចាក់វ៉ាក់សាំងកូវីដ-១៩..... 22
7.2 បង្កើនសមត្ថភាពស្ថាប័នលើការគ្រប់គ្រងទិន្នន័យ ដូចជាការប្រមូល វិភាគបកស្រាយទិន្នន័យ រៀបចំរបាយការណ៍ និងប្រើប្រាស់របាយការណ៍ ..... 23
7.3 ពង្រឹងយន្តការរាយការណ៍ស្ដីពីការងារចាក់វ៉ាក់សាំង រំហូររបាយការណ៍ សន្តិសុខ ទិន្នន័យ និងឯកជនភាព ..... 24
7.4 ការវាយតម្លៃនៃការបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ..... 25
8 គម្រោងចំណាយ..... 26

# សេចក្តីសង្ខេប

1. ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បានដាក់ចេញនូវយុទ្ធសាស្ត្រ សកម្មភាព និង និតិវិធី ដែលត្រូវអនុវត្តដើម្បីជំរុញការងារចាក់វ៉ាក់សាំងកូវីដ-១៩ នៅក្នុងក្របខណ្ឌទូទាំងប្រទេស ឱ្យបានទាន់ពេលវេលា មានសុវត្ថិភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយមានការចូលរួមពីក្រសួង-ស្ថាប័នអាជ្ញាធរមានសមត្ថកិច្ច ភាគីពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍ និងសហគមន៍ ទូទាំងប្រទេស ។

2. ការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវផ្សាភ្ជាប់នឹងការអនុវត្តវិធានការ « ៣ ការពារ និង ៣ កុំ» និងការពង្រឹងប្រព័ន្ធសន្តិសុខសុខភាពជាតិ នេះជាជំហានដ៏សំខាន់ក្នុងការវិលត្រឡប់ជាបណ្តើរៗ ទៅកាន់ភាពប្រក្រតីនៃការរស់នៅតាមបែបគន្លងថ្មី ជាពិសេសការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំខាងមុខ។

3. សន្និទានកម្ម៖ ចាក់វ៉ាក់សាំងកូវីដ-១៩ គឺជាមធ្យោបាយមួយ ក្នុងចំណោមវិធានការសុខាភិបាលចាំបាច់ដទៃទៀត ដែលនឹងបង្ការការចម្លងជំងឺកូវីដ-១៩ និងកាត់បន្ថយផលប៉ះពាល់នៃជំងឺនេះ ទៅលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។

4. គោលបំណង៖ ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មានគោលបំណង “ ការពារប្រជាពលរដ្ឋពីជំងឺកូវីដ-១៩ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវការឈឺសម្រាកពេទ្យនិងស្លាប់ ការពារប្រព័ន្ធសុខាភិបាល និងកាត់បន្ថយផលប៉ះពាល់ដល់ស្ថានភាពសង្គម-សេដ្ឋកិច្ច” ។

5. គោលដៅ៖ “ប្រជាពលរដ្ឋគោលដៅនៅក្នុងប្រទេសកម្ពុជា ១០លាន នាក់ ឬ ៦២% នៃប្រជាពលរដ្ឋសរុបបានចាក់វ៉ាក់សាំងកូវីដ-១៩ និងអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ លើសពី ៩៥% នៃប្រជាពលរដ្ឋគោលដៅបានចាក់វ៉ាក់សាំងនៅត្រឹមពាក់កណ្តាលឆ្នាំ២០២២” តាមរយៈការចាក់វ៉ាក់សាំងកូវីដ-១៩ ទាន់ពេលវេលា មានសុវត្ថិភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

6. គោលការណ៍នៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩៖ (១)ស្ម័គ្រចិត្តនិងមិនបង់ថ្លៃ (២)កំណត់ប្រជាពលរដ្ឋគោលដៅជាអាទិភាពសម្រាប់ការចាក់វ៉ាក់សាំងតាមជំហានៗ (៣) សុវត្ថិភាព និងប្រសិទ្ធភាព និង(៤) រក្សានិរន្តភាពនៃការផ្តល់សេវាសុខភាពជាសារវន្តជាប្រចាំ។

7. យុទ្ធសាស្ត្រនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ផ្តោតលើ ៦ ផ្នែក ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នានិងគាំទ្រគ្នាទៅវិញទៅមក៖ (១)អភិក្រមនៃការចាក់វ៉ាក់សាំង (២)ដឹកនាំ គ្រប់គ្រង ផែនការ និងសម្របសម្រួល (៣) ធនធានមនុស្ស (៤)គ្រប់គ្រងនិងបែងចែកវ៉ាក់សាំង និងគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំង (៥)ការប្រាស្រ័យទាក់ទង និងការចូលរួមរបស់សហគមន៍ និង (៦)ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ។

## យុទ្ធសាស្ត្រនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

8. អភិក្រមនៃការចាក់វ៉ាក់សាំងកូវីដ-១៩៖ (១)ការចាក់វ៉ាក់សាំងកូវីដ-១៩ ប្រព្រឹត្តទៅតាមដំណាក់កាល ៣ បន្តបន្ទាប់គ្នា។ ក្រុមប្រជាពលរដ្ឋគោលដៅអាទិភាពដែលត្រូវចាក់មុនគេ គឺប្រជាពលរដ្ឋដែលប្រឈមហានិភ័យខ្ពស់ងាយឆ្លងជំងឺកូវីដ-១៩ ដូចជាក្រុមគ្រូពេទ្យ កងកម្លាំងអន្តរាគមន៍ កងទ័ព នគរបាលជួរមុខ ប្រជាពលរដ្ឋមានអាយុចាប់ពីអាយុ៦០ឡើង កម្មករ និយោជិតក្នុងវិស័យជួរមុខ ជាដើម ។ (២)ការចាក់វ៉ាក់សាំងកូវីដ-១៩ ធ្វើឡើងតាមយន្តការពីរ៖ នៅនឹងកន្លែង(ចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែករាជធានី-ខេត្ត មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព)និង ចល័ត (ចាក់វ៉ាក់សាំងកូវីដ-១៩នៅតាមមណ្ឌលចាក់វ៉ាក់សាំងកូវីដ-១៩ ដែលត្រូវបានរៀបចំឡើង ដូចជានៅតាមក្រសួង-ស្ថាប័ន ពហុកីឡដ្ឋាន រោងចក្រ សាលារៀន ឬទីតាំងសាធារណៈណាមួយដែលសមស្រប។ (៣) ដំណើរការចាក់វ៉ាក់បង្ការជំងឺកូវីដ-១៩៖ ការចុះឈ្មោះចាក់វ៉ាក់សាំងជាមុនតាមប្រព័ន្ធអេឡិចត្រូនិច www.cambodia-vaccine.gov.kh (៤)សមត្ថភាពនៃការចាក់វ៉ាក់សាំងកូវីដ-១៩៖ ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បានកំណត់គោលដៅចាក់វ៉ាក់សាំង ឱ្យបាន ១លាន ដូស ក្នុងមួយខែ។ តាមការប៉ាន់ស្មាន គោលដៅនេះត្រូវការក្រុមការងារចាក់វ៉ាក់សាំងកូវីដ-១៩ យ៉ាងតិច ពី២០០-២៥០ក្រុម ឬមនុស្សចំនួនពី ២.០០០-២៥០០នាក់ ក្នុងក្របខណ្ឌទូទាំងប្រទេស។

9. ការងារដឹកនាំ គ្រប់គ្រង ផែនការ និងសម្របសម្រួល ផ្តោតលើ៖(១)ពង្រឹងការដឹកនាំ និងគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ (២)រៀបចំផែនការសកម្មភាពសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (៣)លើកកម្ពស់ការអនុវត្តផែនការ និងតាមដានត្រួតពិនិត្យជាប្រចាំនូវវឌ្ឍភាពឆ្ពោះទៅសម្រេចគោលដៅនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ និង(៤)លើកកម្ពស់ការសម្របសម្រួលក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ។

10. ធនធានមនុស្ស ផ្តោតលើ៖ (១)រៀបចំផែនការតម្រូវការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (២)បណ្តុះបណ្តាលធនធានមនុស្សសម្រាប់យុទ្ធនាការនៃការចាក់វ៉ាក់សាំងកូវីដ-១៩ (៣)បណ្តុះបណ្តាលបំប៉នផ្នែកគ្លីនិកស្តីពីការគ្រប់គ្រងផលរំខានក្រោយការចាក់វ៉ាក់សាំង (៤)ត្រួតពិនិត្យតាមដាន និងអភិបាលការប្រតិបត្តិគោលការណ៍ណែនាំ ឬពិធីសារនៃការងារចាក់វ៉ាក់សាំង។

11. ការគ្រប់គ្រងវ៉ាក់សាំងនិងការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ ផ្តោតលើ៖ (១)ការគ្រប់គ្រងនិងបែងចែកវ៉ាក់សាំងនិងសម្ភារៈបរិក្ខារ (២)ការគ្រប់គ្រងប្រព័ន្ធត្រជាក់ដើម្បីថែរក្សាសុវត្ថិភាព និងប្រសិទ្ធភាពវ៉ាក់សាំង (៣)ការគ្រប់គ្រងបញ្ជីសារពើភណ្ឌវ៉ាក់សាំង និង(៤)ការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំង។

12. ការប្រាស្រ័យទាក់ទង និងការចូលរួមរបស់សហគមន៍ ផ្តោតលើ៖(១)លើកកម្ពស់ការយល់ដឹងរបស់ប្រជា-ពលរដ្ឋឱ្យចូលរួមចាក់វ៉ាក់សាំងកូវីដ-១៩ (២)លើកកម្ពស់ការយល់ដឹងរបស់គ្រូពេទ្យបុគ្គលិកសុខាភិបាលអំពីអត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំង (៣)យន្តការគ្រប់គ្រងផលរំខានក្រោយពីចាក់វ៉ាក់សាំងកូវីដ-១៩ និង(៤)ពង្រឹងយន្តការដែលមានស្រាប់នៅក្នុងសហគមន៍ដើម្បីគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩។

13. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ្តោតលើ៖ (១) អភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យការងារចាក់វ៉ាក់សាំងកូវីដ១៩ (២)ពង្រឹងសមត្ថភាពគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យ (៣)ពង្រឹងយន្តការត្រួតពិនិត្យតាមដាន និងប្រព័ន្ធរាយការណ៍ និង(៤)ការវាយតម្លៃការងារចាក់វ៉ាក់សាំងបង្ការក្រោយបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំង។

14. គម្រោងចំណាយប៉ាន់ស្មាន សម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស រយៈពេល ៩ខែ(ពីខែមេសា-ធ្នូឆ្នាំ២០២១) មានទឹកប្រាក់សរុប ៨៣.៦២៥.៧៩២.០០០ រៀល (ប៉ែតសិបបីប៊ីលានប្រាំមួយរយម្ភៃប្រាំលាន ប្រាំពីរយកៅសិបពីរពាន់រៀលគត់)ឬស្មើនឹង ២០.៥៩៧.៤៨៦ ដុល្លារអាមេរិក (ម្ភៃលាន ប្រាំរយកៅសិបប្រាំពាន់ បួនរយប៉ែតសិបប្រាំមួយដុល្លារអាមេរិក) ដោយមិនបញ្ចូលតម្លៃវ៉ាក់សាំងកូវីដ-១៩)។

15. ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គឺជា “ឯកសាររស់” ដែលត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំក្នុងលក្ខណៈទៀងទាត់ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍជាក់ស្តែងតាមដំណាក់កាលនិមួយៗ នៃយុទ្ធនាការចាក់វ៉ាំងសាំងកូវីដ-១៩ ដោយយោងទៅតាមលទ្ធផលនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

# 1 សេចក្ដីផ្ដើម

## 1.1 សន្និទានកម្ម

ការចាក់វ៉ាក់សាំងកូវីដ-១៩ គឺជាមធ្យោបាយមួយ ក្នុងចំណោមវិធានការសុខាភិបាលចាំបាច់ដទៃទៀត ដែលនឹងបង្ការការរាតត្បាតការចម្លងជំងឺកូវីដ-១៩ និងកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ ការអនុវត្តវិធានការ « ៣ ការពារ និង ៣ កុំ» ការពង្រឹងប្រព័ន្ធសន្តិសុខសុខភាពជាតិ (ប្រព័ន្ធអង្កេតតាមដាន និងឆ្លើយតបជំងឺឆ្លង និងគ្រោះអាសន្នសុខភាពសាធារណៈ) និងការចាក់វ៉ាក់សាំងដែលមាន ប្រសិទ្ធភាព និងសុវត្ថិភាពបង្ការជំងឺកូវីដ-១៩ នឹងការពារប្រជាពលរដ្ឋកម្ពុជាពីការចម្លងនៃជំងឺកូវីដ-១៩ ជាជំហានសំខាន់មួយក្នុងការវិលត្រឡប់ជាបណ្ដើរៗ ទៅកាន់ការរស់នៅប្រកបដោយសុវត្ថិភាពតាមបែបគន្លងថ្មី ជាពិសេសការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំខាងមុខ ។

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងតាមយន្តការនានា ក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគី ដើម្បីទទួលបានវ៉ាក់សាំងកូវីដ-១៩ សម្រាប់ចាក់ជូនប្រជាពលរដ្ឋ។ ជាក់ស្តែងប្រទេសកម្ពុជាបានទទួលវ៉ាក់សាំង Sinopharm ជាអំណោយរបស់សាធារណរដ្ឋប្រជាមានិតចិន ចំនួន ៦០០.០០០ដូស នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២១ វ៉ាក់សាំង AstraZeneca (CoviShield™) ចំនួន ៣២៤.០០០ ដូស តាមរយៈមជ្ឈមណ្ឌល COVAX នៅថ្ងៃទី ២ ខែមិនា ឆ្នាំ២០២១ និងវ៉ាក់សាំង Sinovac ១,៥ លានដូស នៅថ្ងៃ ២៦ មិនា ឆ្នាំ២០២១។ ការវ៉ាក់សាំងកូវីដ-១៩ ឈរលើគោលការណ៍ស្ម័គ្រចិត្ត និងមិនបង់ថ្លៃ សម្រាប់ប្រជាពលរដ្ឋគោលដៅអាទិភាព ដោយដំណាក់កាលដំបូងបានចាប់ផ្ដើមនៅថ្ងៃ១០ ខែកុម្ភៈ ឆ្នាំ២០២១។ វ៉ាក់សាំងកូវីដ-១៩ នឹងមកដល់ប្រទេសកម្ពុជា ជាបន្តបន្ទាប់នៅក្នុងអំឡុងពេលខាងមុខនេះ ។

ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ជាមគ្គុទេសក៏សម្រាប់ជំរុញការងារចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានទាន់ពេលវេលា មានសុវត្ថិភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយប្រែក្លាយ «ផែនការជាតិស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩» ដែលបានដាក់ចេញនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ឱ្យទៅជាសកម្មអនុវត្តជាក់ស្តែង តាមរយៈការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ វិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ និងសហគមន៍ ទូទាំងប្រទេស។

## 1.2 គោលបំណង

ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស មានគោលបំណង " ការពារប្រជាពលរដ្ឋកម្ពុជាពីជំងឺកូវីដ-១៩ ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវការឈឺសម្រាកពេទ្យ និងស្លាប់ ការពារប្រព័ន្ធសុខាភិបាល និងកាត់បន្ថយផលប៉ះពាល់ដល់ស្ថានភាពសង្គម-សេដ្ឋកិច្ច" ។

## 1.3 គោលដៅ

ដើម្បីសម្រេចគោលបំណងខាងលើនេះ គោលដៅ នៃផែនការគឺ "ប្រជាពលរដ្ឋគោលដៅ នៅក្នុងប្រទេសកម្ពុជា ១០លាន នាក់ ឬ ៦២% នៃប្រជាពលរដ្ឋសរុបបានចាក់វ៉ាក់សាំងកូវីដ-១៩ និងអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ លើសពី ៩៥% នៃប្រជាពលរដ្ឋគោលដៅបានចាក់វ៉ាក់សាំងនៅត្រឹមពាក់កណ្តាលឆ្នាំ២០២២" តាមរយៈយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ឱ្យទាន់ពេលវេលា មានសុវត្ថិភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

## 1.4 គោលការណ៍នៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

កិច្ចដំណើរការនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ឈរលើគោលការណ៍ខាងក្រោម៖

- ស្ម័គ្រចិត្ត និងមិនបង់ថ្លៃ
- កំណត់ប្រជាពលរដ្ឋគោលដៅអាទិភាពសម្រាប់ការចាក់វ៉ាក់សាំងតាមដំណាក់កាលនិមួយៗ
- សុវត្ថិភាព និងប្រសិទ្ធភាព
- រក្សានិរន្តភាពនៃការផ្តល់សេវាសុខភាពជាសារវ័ន្ត

- **ស្ម័គ្រចិត្ត និងមិនបង់ថ្លៃ**

  រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ តាមការស្ម័គ្រចិត្ត និងដោយមិនបង់ថ្លៃ ។

- **កំណត់ប្រជាពលរដ្ឋគោលដៅជាអាទិភាពសម្រាប់ការចាក់វ៉ាក់សាំងតាមដំណាក់កាលនិមួយៗ**

  ប្រជាពលរដ្ឋគោលដៅនៃការចាក់វ៉ាក់សាំង គឺប្រជាពលរដ្ឋកម្ពុជា និងជនបរទេសដែលរស់នៅ និងធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។ ក្រុមគោលដៅអាទិភាពដែលត្រូវចាក់វ៉ាក់សាំងមុនគេ គឺជាក្រុមប្រជាពលរដ្ឋ ដែលមានហានីភ័យខ្ពស់ងាយឆ្លងជំងឺកូវីដ-១៩ ដូចជាក្រុមគ្រូពេទ្យ កងកម្លាំងអន្តរាគមន៍ កងទ័ព នគរបាលជួរមុខ ប្រជាពលរដ្ឋមានអាយុចាប់ពីអាយុ៦០ឡើង។

- **សុវត្ថិភាព និងប្រសិទ្ធភាព**

  វ៉ាក់សាំងកូវីដ-១៩ ដែលត្រូវបានប្រើប្រាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាប្រភេទវ៉ាក់សាំងដែលស្ថិតក្នុង «បញ្ជីវ៉ាក់សាំងដែលអនុញ្ញាតិឱ្យប្រើប្រាស់បន្ទាន់» របស់អង្គការសុខភាពពិភពលោក និងប្រភេទវ៉ាក់សាំងដែលត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ដោយក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

ដំណើរការនៃការចាក់វ៉ាក់សាំងនៅតាមទីតាំងចាក់វ៉ាក់សាំងទូទាំងប្រទេស ត្រូវអនុលោមតាមពិធីសារនៃការចាក់វ៉ាក់សាំង និងអនុវត្តយ៉ាងម៉ត់ចត់នូវវិធានការសុខាភិបាល ដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃការចាក់វ៉ាក់សាំង និងចៀសវាងនូវការចម្លងកូវីដ-១៩ ដោយធានាថាទីតាំងនៃការចាក់វ៉ាក់សាំងមិនក្លាយជាប្រភពនៃការចម្លងជំងឺកូវីដ-១៩ ។

### រក្សានិរន្តភាពនៃការផ្តល់សេវាសុខភាពសារវន្តជាប្រចាំ

ដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ គប្បីធ្វើឱ្យលឿនតាមដែលអាចធ្វើទៅបាន នៅពេលដែលបរិមាណវ៉ាក់សាំងអាចមានកាន់តែច្រើនឡើង។ ក្នុងបរិការណ៍នេះ អង្គភាពគ្រប់ជាន់ថ្នាក់(ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ត្រូវរៀបចំផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងឱ្យបានច្បាស់លាស់ជាពិសេសកម្លាំងធនធានមនុស្ស ដើម្បីកុំឱ្យមានការរអាក់រអួលដល់ការផ្តល់សេវាសុខភាពជាសារវន្ត ជាប្រចាំជូនប្រជាពលរដ្ឋ ជាពិសេសនៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។

ក្នុងករណី រាំងស្ទះដល់ដំណើរការចែកចាយវ៉ាក់សាំងដល់តាមគោលដៅ ខ្វះខាតគ្រូពេទ្យ បុគ្គលិក គប្បីចាត់វិធានការជាបន្ទាន់ និងកៀរគរកម្លាំងបន្ថែមសម្រាប់ជួយដល់ដំណើរការចាក់វ៉ាក់សាំង ដូចជាពន្លឿនប្រព័ន្ធចែកចាយវ៉ាក់សាំង បន្ថែមក្រុមគ្រូពេទ្យ និងអ្នកស្ម័គ្រចិត្ត ជាដើម។

## 1.5 យុទ្ធសាស្ត្រនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

យុទ្ធសាស្ត្រនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ផ្តោត ៦ ផ្នែក ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា៖

១. អភិក្រមនៃការចាក់វ៉ាក់សាំង
២. ការដឹកនាំ គ្រប់គ្រង ផែនការ និងសម្របសម្រួល
៣. ធនធានមនុស្ស
៤. ការគ្រប់គ្រងនិងបែងចែកវ៉ាក់សាំង និងការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំង
៥. ការប្រាស្រ័យទាក់ទង និងការចូលរួមរបស់សហគមន៍
៦. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

# 2 អាទិភាពនៃការចាក់វ៉ាក់សាំង

## 2.1 ដំណាក់កាលនៃយុទ្ធនាការចាក់វ៉ាក់សាំង និងប្រជាពលរដ្ឋគោលដៅ

យោងតាមជំរឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ប្រជាពលរដ្ឋមានអាយុចាប់ពី១៨ឆ្នាំឡើងមានចំនួនសរុប១០.១៤១.៣៤០នាក់ក្នុងនោះប្រជាពលរដ្ឋអាយុពី១៨-៥៩ឆ្នាំមានចំនួន៨.៧៦២.៦៥២នាក់ និងអាយុពី ៦០ឆ្នាំឡើង មានចំនួន ១.៣៧៨.៦៨៨នាក់ ។ យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នឹងប្រព្រឹត្តទៅជាដំណាក់កាល ៣ បន្តបន្ទាប់គ្នា លើប្រជាពលរដ្ឋគោលដៅតាមលំដាប់អាទិភាព។ ក្រុមប្រជាពលរដ្ឋគោលដៅជាអាទិភាពសម្រាប់ការចាក់វ៉ាក់សាំងនឹងត្រូវបានកំណត់សម្រាប់ដំណាក់កាលនីមួយៗ។ វឌ្ឍនភាពនៃការគ្របដណ្តប់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ លើក្រុមប្រជាពលរដ្ឋគោលដៅអាទិភាព តាមដំណាក់កាលនីមួយៗ នឹងត្រូវបានពិនិត្យតាមដាន និងធ្វើបច្ចុប្បន្នកម្មជាទៀងទាត់។ ក្រុមប្រជាពលរដ្ឋគោលដៅត្រូវបានពិនិត្យ និងកែសម្រួលយោងទៅតាមស្ថានភាពជាក់ស្តែង រួមមានជាអាទិ៍ កម្រិតហានិភ័យនៃចម្លងរាតត្បាតតាមតំបន់ភូមិសាស្រ្ត និងក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះជាងគេ ជាដើម។

### គំនូសបំព្រួញបង្ហាញពីដំណាក់កាលចាក់វ៉ាក់សាំងកូវីដ-១៩ និងក្រុមប្រជាពលរដ្ឋគោលដៅ

**ដំណាក់កាលទី១**
កុម្ភៈ-មិថុនា ២០២១

- ក្រុមគ្រូពេទ្យ បុគ្គលិកសុខាភិបាល(រដ្ឋនិងឯកជន)អ្នកស្ម័គ្រចិត្តក្នុងសហគមន៍(ឧ.ក្រុមទ្រទ្រង់សុខភាពភូមិ) និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត
- ថ្នាក់ដឹកនាំ-មន្ត្រីនៃស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលាការ ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន-អង្គភាព
- កងកម្លាំងអន្តរាគមន៍ កងទ័ព នគរបាលជួរមុខ និងមន្ត្រីមូលដ្ឋាន
- មន្ត្រីរាជការ រួមទាំងបុគ្គលិកកិច្ចសន្យា និងបុគ្គលិកសិក្សានៃគ្រឹះស្ថានបណ្តុះបណ្តាលឯកជន
- មន្ត្រី-បុគ្គលិកគ្រឹះស្ថាន-សហគ្រាសសាធារណៈ
- ប្រជាពលរដ្ឋវ័យចាស់អាយុពី៦០ឡើង
- ប្រជាពលរដ្ឋអាយុពី១៨-៦៤ឆ្នាំមានជំងឺប្រចាំកាយ(ទឹកនោមផ្អែម ឡើងសម្ពាធឈាម.......)
- កម្មករ និយោជិត និយោជក់ជួរមុខ សហជីព តាមរោងចក្រ សហគ្រាស
- មន្ត្រី-បុគ្គលិកស្ថានទូត និងអង្គការអន្តរជាតិ

**ដំណាក់កាលទី២**
កក្កដា-ធ្នូ ២០២១

- កម្មករ និយោជិត និយោជក់ ផ្សេងទៀត
- ប្រជាពលរដ្ឋក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ប្រជាពលរដ្ឋអាយុពី១៨ឆ្នាំឡើងផ្សេងទៀត

**ដំណាក់កាលទី៣**
មករា-មិថុនា ២០២២

- ប្រជាពលរដ្ឋគោលដៅដទៃទៀត

## 2.2 យន្តការនៃការចាក់វ៉ាក់សាំង

ការចាក់វ៉ាក់សាំងប្រព្រឹត្តទៅ តាមយន្តការ ២៖

- **នៅនឹងកន្លែង** គឺ ចាក់វ៉ាក់សាំងនៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែករាជធានី-ខេត្ត មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី-ខេត្ត និងមន្ទីរពេទ្យឬមូលដ្ឋានសុខាភិបាល ដែលគ្រប់គ្រងដោយអង្គភាពកងកម្លាំងប្រដាប់អាវុធ និងអង្គភាពនគរបាល។
- **ចល័ត** គឺចាក់វ៉ាក់សាំងនៅតាមមណ្ឌលចាក់វ៉ាក់សាំង ដែលត្រូវបានរៀបចំឡើង នៅតាមក្រសួង-ស្ថាប័ន ពហុកីឡាដ្ឋាន រោងចក្រ សាលារៀន ឬទីតាំងសាធារណៈណាមួយដែលសមស្រប ហើយដែលត្រូវបានកំណត់ដោយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស និងអនុ-គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ។
    - នៅថ្នាក់ជាតិ៖ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងក្រសួង-ស្ថាប័ន ជាអ្នកទទួលខុសត្រូវក្នុងការកំណត់និងរៀបចំទីតាំងចាក់វ៉ាក់សាំងដោយសហការនិងសម្រួលជាមួយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស។
    - នៅថ្នាក់ក្រោមជាតិ៖ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងនៃរដ្ឋបាលរាជធានី-ខេត្ត ជាអ្នកទទួលខុសត្រូវក្នុងការកំណត់ និងរៀបចំទីតាំងចាក់វ៉ាក់សាំង ដោយសហការនិងសម្របសម្រួល ជាមួយអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួង-ស្ថាប័នពាក់ព័ន្ធដែលមានភារកិច្ចរៀបចំបញ្ជីឈ្មោះអ្នកចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត (ឧ.ការរៀបចំមណ្ឌលចាក់វ៉ាក់សាំងសម្រាប់កម្មករ-និយោជិតនៃរោងចក្រសហគ្រាស នៅតាមរាជធានី-ខេត្ត ជាសមត្ថកិច្ចរបស់អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងរាជធានី-ខេត្ត និងអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិរបបសន្តិសុខសង្គម។

## 2.3 កិច្ចដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩

### 2.3.1 ការចុះឈ្មោះចាក់វ៉ាក់សាំងទុកជាមុន

ជាគោលការណ៍ដើម្បីទទួលបានការចាក់វ៉ាក់សាំង អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវចុះឈ្មោះជាមុនតាមគេហទំព័រ www.cambodia-vaccine.gov.kh ។ ការចុះឈ្មោះនេះអាចធ្វើឡើងដោយបុគ្គលអ្នកស្មគ្រ័ចិត្តចាក់វ៉ាក់សាំងខ្លួនឯង ឬដោយអ្នកជួយ។

យោងតាមស្ថានភាពជាក់ស្តែង អនុគណៈកម្មការចំពោះកិច្ចក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ឬអាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធ អាចរៀបចំបញ្ជីឈ្មោះអ្នកចាក់ស្មគ្រ័ចិត្តចាក់វ៉ាក់សាំង ដែលស្ថិតក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន រួចចុះឈ្មោះជាមុនក្នុងគេហទំព័រ www.cambodia-vaccine.gov.kh (ឧ.រដ្ឋបាលឃុំសង្កាត់

ជួយរៀបចំបញ្ជី និងជួយចុះឈ្មោះឱ្យប្រជាពលរដ្ឋចាស់ៗ រស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន សម្រាប់ការចាក់វ៉ាក់សាំងកូវីដ-១៩)។

### 2.3.2 ការរៀបចំទីកន្លែងសម្រាប់កិច្ចដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩

កិច្ចដំណើរការចាក់វ៉ាក់សាំងត្រូវប្រព្រឹត្តទៅតាមផែនការសកម្មភាពដែលបានគ្រោងទុក និងតាមគោល-ការណ៍ណែនាំបច្ចេកទេស និងនីតិវិធីដែលបានកំណត់ ដើម្បីឱ្យដំណើរការចាក់វ៉ាក់សាំងប្រព្រឹត្តទៅបានលឿនតាមដែលអាចធ្វើទៅបាន មានរបៀបរៀបរយ និងធានាបាននូវសុវត្ថិភាព ក្នុងការទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩។ គំនូសបំព្រួញខាងក្រោមបង្ហាញអំពីការរៀបចំទីតាំងចាក់វ៉ាក់សាំង និងរំហូរនៃកិច្ចដំណើរការចាក់វ៉ាក់សាំង នៅតាមទីតាំងចាក់វ៉ាក់សាំងនិមួយៗ និងចំនួនសមាជិកនៃក្រុមការងារចាក់វ៉ាក់សាំងដែលត្រូវមាន។ យោងតាមស្ថានភាពជាក់ស្តែង ឬតម្រូវការចាំបាច់ដើម្បីបង្កើនល្បឿននៃការចាក់វ៉ាក់សាំង ក្នុងករណីអ្នកចាក់វ៉ាក់សាំងច្រើន ចំនួនសមាជិកក្នុងក្រុមការងារ និង/ឬ ចំនួនក្រុមការងារអាចត្រូវបានបន្ថែម ជាពិសេសចំនួនអ្នកចាក់វ៉ាក់សាំងផ្ទាល់អាចលើសពី ២នាក់។ គួរកត់សម្គាល់ថា នៅទីតាំងចាក់វ៉ាក់សាំងមួយ អាចមានក្រុមការងារចាក់វ៉ាក់សាំងលើសពីមួយក្រុម (ឧ. មន្ទីរពេទ្យមួយ ឬមណ្ឌលចាក់វ៉ាក់សាំងមួយកន្លែងអាចមានក្រុមចាក់វ៉ាក់សាំងលើសពីមួយក្រុម ដែលអាចដំណើរការនៅពេលតែមួយ។ នៅតាមទីតាំងចាក់វ៉ាក់សាំងគួររៀបចំឱ្យមាន គំនូសបំព្រួញបង្ហាញផ្លូវដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកមកចាក់វ៉ាក់សាំង និងមានផ្ទាំងរូបភាពអប់រំណែនាំខ្លីៗ ដែលអ្នកមកចាក់វ៉ាក់សាំង អាចមើលបានខណៈពេលអង្គុយរង់ចាំ។

### 2.3.3 ក្រុមការងារចាក់វ៉ាក់សាំង

ក្រុមការងារចាក់វ៉ាក់សាំង ក្នុង១ ក្រុម មាន គ្នា ១០ នាក់ ក្នុងនោះរួមមាន៖

- គ្រូពេទ្យ ១ នាក់
- គិលានុបដ្ឋាក-យិកាជំនួយការគ្រូពេទ្យ ១ នាក់
- បុគ្គលិកចាក់វ៉ាក់សាំង ២ នាក់
- បុគ្គលិកកត់ត្រាទិន្នន័យ ២ នាក់
- បុគ្គលិកជំនួយ ៣ នាក់ (ពិនិត្យវិធានសុខាភិបាល នៅប្រកទ្វារចូល និងសម្របសម្រួលនៅកន្លែងរង់ចាំមុនពេលចាក់វ៉ាក់សាំង)
- មន្ត្រីអភិបាល(ប្រធានក្រុមការងារ) ១ នាក់

សម្រាប់ទីតាំងចាក់វ៉ាក់សាំងចល័ត គប្បីគិតបញ្ចូល៖

- ក្រុមរថយន្តគិលានសង្គ្រោះ (ក្នុងករណីចាំបាច់ត្រូវមាន)
- ក្រុមដឹកជញ្ជូនវ៉ាក់សាំង

ផ្អែកលើបទពិសោធន៍នៃកិច្ចដំណើរការចាក់វ៉ាក់សាំងកន្លងមក និងយោងតាមស្ថានភាពជាក់ស្ដែងនៅនឹងកន្លែង ដើម្បីឱ្យកិច្ចដំណើរការចាក់វ៉ាក់សាំងប្រព្រឹត្តទៅបានកាន់តែប្រសើរ នៅតាមទីកន្លែងក្នុងទីតាំងចាក់វ៉ាក់សាំង គួរបន្ថែមបុគ្គលិកនៅ៖

- ប្រកទ្វារចូល(ទី១) គួរមានបុគ្គលិកយ៉ាងតិច ៣ នាក់ ដោយសារចាំបាច់ត្រូវមានបុគ្គលិកម្នាក់ (អាចជាភ្នាក់ងារសន្តិសុខ)ចល័តតាមជួរអ្នកចាក់វ៉ាក់សាំងដើម្បីពង្រឹងការរក្សាគម្លាតសុវត្ថិភាព។
- កន្លែងពិនិត្យសុខភាព(ទី៣)គួរបន្ថែមបុគ្គលិកដោយសារនៅទីនេះត្រូវចំណាយពេលវេលាច្រើន។
- កន្លែងកត់ត្រាទិន្នន័យ(ទី៤) គួរបន្ថែមបុគ្គលិកនិងត្រៀមឯកសារកត់ត្រាដោយដៃ ក្នុងករណីប្រព័ន្ធប្រមូលទិន្នន័យអេឡិចត្រូនិករអាក់រអួល ឬមិនដំណើរការ ។
- កន្លែងចាក់វ៉ាក់សាំង (៥) គួរមានអ្នកចាក់វ៉ាក់សាំងពី ២-៦ នាក់។

## គំនូសបំព្រួញបង្ហាញពីរបៀបនៃកិច្ចដំណើរការចាក់វ៉ាក់សាំងនៅទីតាំងចាក់វ៉ាក់សាំង និងក្រុមការងារចាក់វ៉ាក់សាំង



ដើម្បីឱ្យកិច្ចដំណើរការចាក់វ៉ាក់សាំង ត្រូវអនុវត្តតាមផែនការដែលបានគ្រោងទុក សកម្មភាពសំខាន់ៗ មួយចំនួនដែលត្រូវយកចិត្តទុកដាក់ រួមមានជាអាទិ៍៖

- ផ្តល់ការចាក់វ៉ាក់សាំងនៅមូលដ្ឋានសុខាភិបាល
- ផ្តល់ការចាក់វ៉ាក់សាំងនៅសហគមន៍ដាច់ស្រយាលដោយក្រុមចាក់វ៉ាក់សាំងចល័ត
- តាមដានរាល់ថ្ងៃ ការបំពេញមុខងារក្នុងយុទ្ធនាការចាក់វ៉ាក់សាំង និងលទ្ធផលសម្រេចបាន ទៅតាមក្រុមប្រជាពលរដ្ឋគោលដៅ និងតាមប្រភេទវ៉ាក់សាំង
- ផ្តល់ការអភិបាលគាំទ្រទៅដល់ទីតាំងចាក់វ៉ាក់សាំង
- ផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខាសម្រាប់ចាក់វ៉ាក់សាំង រួមទាំងសម្ភារៈបរិក្ខា សម្រាប់ការពារបុគ្គល ទៅទីតាំងចាក់វ៉ាក់សាំង ដើម្បីបំពេញកង្វះខាត
- ការផ្តល់វ៉ាក់សាំងនៅតំបន់ដែលមានអត្រាគ្របដណ្តប់ទាបក្នុងក្រុមគោលដៅ
- ត្រៀមលក្ខណៈទុកជាមុនឱ្យបានសមស្របសម្រាប់ដំណើរការចាក់វ៉ាក់សាំងនៅក្នុងរដូវភ្លៀងខាងមុខ។

## 2.4 សមត្ថភាពនៃការចាក់វ៉ាក់សាំង

យុទ្ធនាការនៃការចាក់វ៉ាក់សាំងត្រូវបានពិនិត្យតាមដានជាប្រចាំ នូវលទ្ធផលនៃការចាក់វ៉ាក់សាំង និងពិនិត្យមើលល្បឿននៃការចាក់វ៉ាក់សាំងប្រចាំថ្ងៃ ប្រចាំសប្តាហ៍...នៅតាមទីតាំងនិមួយៗ ធ្វើយ៉ាងណាឱ្យការចាក់វ៉ាក់សាំងបានលឿន ដើម្បីពង្រីកការគ្របដណ្តប់នៃការចាក់វ៉ាក់សាំងលើប្រជាពលរដ្ឋគោលដៅឱ្យបានឆាប់។

ការពង្រីកអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ មិនចំណុះលើធនធានមនុស្ស និងចំនួនទីតាំងចាក់ ប៉ុណ្ណោះទេ ប៉ុន្តែក៏អាស្រ័យលើកត្តាជាសារវន្តមួយចំនួនផងដែរ ដែលរួមមានជាអាទិ៍៖

- ចំនួនប្រជាពលរដ្ឋគោលដៅដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំង
- បរិមាណវ៉ាក់សាំងដែលមានសម្រាប់ទុកចាក់
- សមត្ថភាពស្តុកវ៉ាក់សាំងនៅឃ្លាំងឱសថកណ្តាលនៅរាជធានីភ្នំពេញ និងតាមរាជធានី-ខេត្ត និងស្រុកប្រតិបត្តិ។
- ប្រព័ន្ធគាំទ្រផ្សេងទៀតដែលចាំបាច់បំរើឱ្យការងារចាក់វ៉ាក់សាំង ។

ទោះជាដូច្នេះក្តី ផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេសបានកំណត់គោលដៅនៃការចាក់វ៉ាក់សាំងប្រចាំខែពី ១ លានដូស។ ក្នុងន័យនេះ គ.វ.ក-១៩ និងអនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត និងមូលដ្ឋានសុខាភិបាលគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំផែនការសម្រាប់ការចាក់វ៉ាក់សាំងពិសេសធនធានមនុស្សឱ្យបានសមស្របនិងសេវាគាំទ្រចាំបាច់ដទៃទៀត ដើម្បីត្រៀមសមត្ថភាពនៃការចាក់វ៉ាក់សាំងឱ្យបានរួចរាល់សម្រាប់ការចាក់វ៉ាក់សាំងនៅតាមមូលដ្ឋានសុខាភិបាលផង និងនៅតាមទីតាំងចល័តផង។ ដើម្បីសម្រេចគោលដៅខាងលើនេះ តាមការប៉ាន់ប្រមាណយុទ្ធនាការចាក់វ៉ាក់សាំងក្នុងក្របខណ្ឌទូទាំងប្រទេសអាចត្រូវការក្រុមការងារចាក់វ៉ាក់សាំងចំនួន ពី ២០០-២៥០ក្រុម ឬគិតជាចំនួនមនុស្សពី ២.០០០-២.៥០០នាក់។

# 3 ការដឹកនាំ គ្រប់គ្រង ផែនការ និងសម្របសម្រួល

គុណភាព និងភាពបត់បែន នៃការដឹកនាំ គ្រប់គ្រង ចាត់ចែង សម្របសម្រួល និងគាំទ្រ ដល់កិច្ចដំណើរការចាក់វ៉ាក់សាំង យោងតាមការវិវឌ្ឍជាក់ស្តែងនៃការងារចាក់វ៉ាក់សាំង និងស្ថានភាពឆ្លងនៃជំងឺកូវីដ-១៩ ផ្ទាល់គឺជាគន្លឹះ សម្រាប់ភាពជោគជ័យនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងមូល។ យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ មិនគ្រាន់តែ ដើម្បីសម្រេចគោលដៅនៃការគ្របដណ្តប់វ៉ាក់សាំងលើប្រជាពលរដ្ឋគោលដៅប៉ុណ្ណោះទេ ប៉ុន្តែត្រូវរួមចំណែកជាសារវ័ន្តដល់ការបង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ការចម្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ផងដែរ។ ការណ៍នេះ ទាមទារឱ្យមានការប្រើប្រាស់ឱ្យអស់សក្តានុពល និងប្រកបដោយប្រសិទ្ធភាព នូវធនធានហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធ និងយន្តការដែលមានស្រាប់ ដើម្បីសម្រេចគោលដៅនៃការចាក់វ៉ាក់សាំងផង និងឆ្លើយតបនឹងការចម្លងជំងឺកូវីដ-១៩ ផង។ យុទ្ធនាការចាក់វ៉ាក់សាំងនេះក៏ជាឱកាសដើម្បីពង្រឹងសមត្ថភាពស្ថាប័ន ជាពិសេសប្រព័ន្ធកម្មវិធីជាតិផ្តល់ថ្នាំបង្ការនិងប្រព័ន្ធគាំទ្រដែលមានស្រាប់ចាំបាច់ផ្សេងៗទៀតដែលបម្រើឱ្យយុទ្ធនាការចាក់វ៉ាក់សាំង។

អន្តរាគមន៍លើការងារដឹកនាំ គ្រប់គ្រង ផែនការ និងសម្របសម្រួល ផ្តោតលើសកម្មភាពចម្បងៗ ដូចខាងក្រោមនេះ៖

- ពង្រឹងការដឹកនាំ និងគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- កសាងផែនការសកម្មភាពសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- លើកកម្ពស់ការអនុវត្តផែនការ និងតាមដានត្រួតពិនិត្យជាប្រចាំនូវ វឌ្ឍភាពឆ្ពោះទៅសម្រេចគោលដៅនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- លើកកម្ពស់ការសម្របសម្រួលទូលំទូលាយក្នុងយុទ្ធនាការចាក់វ៉ាក់សាំង

## 3.1 ពង្រឹងការដឹកនាំ និងគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេសត្រូវបានដឹកនាំ គ្រប់គ្រងនិងសម្របសម្រួលដោយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ៣៧ សសរ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០២១ ដោយមានសមាសភាពចូលរួមពីក្រសួង-ស្ថាប័ន អង្គភាពពាក់ពន្ធ័ និងរដ្ឋបាលរាជធានី-ខេត្តទាំង២៥។

អនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវបានបង្កើតឡើងផងដែរ តាមស្មារតីនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលខាងលើនេះ ត្រូវគ្រប់គ្រង ដឹកនាំ ចាត់ចែង ការងារចាក់វ៉ាក់សាំងកូវីដ-១៩ ទៅតាមតួនាទីដែលបានកំណត់ ក្នុងលិខិតបង្គាប់ការរបស់ក្រសួង-ស្ថាប័នសាមី ដោយសហការសម្របសម្រួលជាមួយ គ.វ.ក-១៩ និងដៃគូពាក់ព័ន្ធផ្សេងៗទៀត។

## 3.2 កសាងផែនការសកម្មភាពសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

- រៀបចំផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និង ផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត។

គ.វ.ក-១៩ ត្រូវរៀបចំផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស តាមដានត្រួតពិនិត្យនិងផ្តល់ការគាំទ្រ ទាំងធនធានមនុស្ស និងថវិកា ដល់ការអនុវត្តផែនការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

អនុគណៈកម្មការចំពោះកិច្ចនៃគ.វ.ក-១៩ និងអនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្តត្រូវរៀបចំ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ខ្លួន ដោយធានាឱ្យបាននូវសង្គតិភាពជាមួយផែនការមេសម្រាប់យុទ្ធនាចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និងតាមដានត្រួតពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានជាប្រចាំនៅក្នុងដែលសមត្ថកិច្ចរបស់ខ្លួន។

## 3.3 លើកកម្ពស់ការអនុវត្តផែនការ និងតាមដានត្រួតពិនិត្យការអនុវត្តផែនការ

គ.វ.ក-១៩ និង អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ រាជធានី-ខេត្ត ត្រូវអនុវត្ត និងតាមដានការអនុវត្តផែនការជាប្រចាំ ដើម្បីពិនិត្យមើលវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅនៃការចាក់វ៉ាក់សាំង នៅក្នុងដែលសមត្ថកិច្ចរបស់ខ្លួន ដើម្បីស្វែងយល់ពី បញ្ហាប្រឈម ឬឧបសគ្គនានា ដែលរាំងស្ទះដល់កិច្ចដំណើរការចាក់វ៉ាក់សាំង ហើយត្រូវមានវិធានការដោះស្រាយឱ្យបានទាន់ពេលវេលា។ ការពិនិត្យតាមដានវឌ្ឍនភាព គប្បីប្រើប្រាស់សូចនាករស្នូលនៃការគ្របដណ្តប់ការចាក់វ៉ាក់សាំងកូវីដ-១៩។

## 3.4 លើកកម្ពស់ការសម្របសម្រួលទូលំទូលាយក្នុងយុទ្ធនាការចាក់វ៉ាក់សាំង

យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នាំមកនូវបញ្ហាប្រឈមផង និងកាលានុវត្តភាពផង ដូច្នេះចាំបាច់ត្រូវលើកកម្ពស់ការសម្របសម្រួលឱ្យមានប្រសិទ្ធភាព លើការងារចាក់វ៉ាក់សាំង និងការងារចាំបាច់ផ្សេងទៀត ជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច ភាគីពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍ សហគមន៍.... ដើម្បីប្រមូលផ្តុំកម្លាំង និងធនធាន សម្រាប់លើកកម្ពស់ការខិតខំប្រឹងប្រែងរួមគ្នាដើម្បីសម្រេចគោលដៅនៃផែនការ។

# 4 ធនធានមនុស្ស

យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវការប្រើប្រាស់ធនធានមនុស្សយ៉ាងច្រើនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ការសម្រេចបានគោលដៅនៃផែនការដែលបានកំណត់ អាស្រ័យលើសមត្ថភាពនៃមូលដ្ឋានសុខាភិបាលដែលបានត្រៀមបម្រុងរួចជាស្រេច នូវធនធានមនុស្សដែលមានបរិមាណគ្រប់គ្រាន់ និងមានគុណភាពខ្ពស់ហើយដែលអាចប្រើប្រាស់បានទាន់ពេលវេលា ទៅតាមផែនការ និងកាលវិភាគនៃចាក់វ៉ាក់សាំង នៅក្នុងដំណាក់កាលនិមួយៗ។

កម្មវិធីជាតិផ្តល់ថ្នាំបង្ការបានបណ្តុះបណ្តាលមន្ត្រី បុគ្គលិក ពាក់ព័ន្ធនឹងការងារចាក់វ៉ាក់សាំង នៅគ្រប់ថ្នាក់ក្នុងប្រព័ន្ធសុខាភិបាល។ ដើម្បីពន្លឿនការគ្របណ្តប់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ផង និងដើម្បីរក្សានិរន្តភាពនៃការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋជាប្រចាំផង យុទ្ធនាការការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវការចាំបាច់ធនជានមនុស្សបន្ថែម ជាពិសេសនៅក្នុងខេត្តដែលគ្រូពេទ្យ បុគ្គលិកសុខាភិបាលមានចំនួនតិចតួច។ ក្នុងករណីនេះ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩និមួយៗ នៃ គ.វ.ក១៩ និងអនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត អាចកៀរគរគ្រូពេទ្យ បុគ្គលិកស្ម័គ្រចិត្ត និងគ្រូពេទ្យ បុគ្គលិកពីក្រសួង-ស្ថាប័ននិងអង្គភាពពាក់ព័ន្ធដទៃទៀតមកបណ្តុះបណ្តាល ហើយឱ្យចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់កូវីដ-១៩ ។

អន្តរាគមន៍នៅក្នុងផ្នែកធនធានមនុស្ស ផ្តោតលើសកម្មភាពចម្បងដូចខាងក្រោម៖

- រៀបចំផែនការតម្រូវការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- បណ្តុះបណ្តាលធនធានមនុស្សយោងតាមតម្រូវការនៃផែនការបណ្តុះបណ្តាល
- បណ្តុះបណ្តាលបំប៉នផ្នែកគ្លីនិកស្តីពីការគ្រប់គ្រងផលរំខានក្រោយការចាក់វ៉ាក់សាំងក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩
- ត្រួតពិនិត្យតាមដាននិងអភិបាលការប្រតិបត្តិគោលការណ៍ណែនាំ/ពិធីសារនៃការងារចាក់វ៉ាក់សាំងកូវីដ-១៩

## 4.1 រៀបចំផែនការតម្រូវការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

អនុគណៈកម្មការចំពោះកិច្ច នៃ គ.វ.ក-១៩ និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវរៀបចំផែនការបណ្តុះ-បណ្តាលធនធានមនុស្សសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យបានច្បាស់លាស់ យោងទៅតាមតម្រូវការជាក់ស្តែងនៃការងារចាក់វ៉ាក់សាំង ដោយសហការ និងសម្របសម្រួលជាមួយភាគីពាក់ព័ន្ធនានា។

មុខសញ្ញានៃធនធានមនុស្សដែលត្រូវបណ្តុះបណ្តាលរួមមាន៖

- ក្រុមការងារចាក់វ៉ាក់សាំង និងអ្នកអភិបាល
- ក្រុមអ្នកគ្រប់គ្រងវ៉ាក់សាំង ប្រព័ន្ធត្រជាក់ និងអ្នកអភិបាលការងារគ្រប់គ្រងវ៉ាក់សាំង
- ក្រុមគ្រូពេទ្យដែលមានភារកិច្ចប្រចាំការនៅទីតាំងចាក់វ៉ាក់សាំង ដែលស្ថិតនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនិងនៅតាមមណ្ឌលចាក់វ៉ាក់សាំង (ឧ. តាមរោងចក្រ សហគ្រាស សាលារៀន ពហុកីឡាដ្ឋាន...)។
- ក្រុមការងារគាំទ្រផ្សេងទៀត ដូចជាមន្ត្រីគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិការ HOTLINE សម្រាប់សុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងជាមួយសាធារណជន
- មន្ត្រី បុគ្គលិក ទទួលភារកិច្ចគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំង
- មន្ត្រីគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិការប្រព័ន្ធតាមដានត្រួតពិនិត្យ (ក្រុមមន្ត្រីព័ត៌មានវិទ្យា)
- មន្ត្រីថ្នាក់មូលដ្ឋាន ដែលអាចសម្របសម្រួលជាមួយថ្នាក់ដឹកនាំមូលដ្ឋានក្នុងការផ្តល់ព័ត៌មាន និងជំរុញឱ្យប្រជាពលរដ្ឋ ជាពិសេសអ្នកមានហានិភ័យខ្ពស់ឱ្យមកចាក់វ៉ាក់សាំង។

## 4.2 បណ្តុះបណ្តាលធនធានមនុស្សយោងតាមតម្រូវការនៃផែនការបណ្តុះបណ្តាល

អនុគណៈកម្មការចំពោះកិច្ចពាក់ព័ន្ធ នៃគ.វ.ក ១៩ ត្រូវសហការ និងសម្រួលសម្រួលជាមួយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងភាគីពាក់ព័ន្ធ ក្នុងការរៀបចំផ្តល់ការបណ្តុះបណ្តាលធនធានមនុស្ស ដោយរាប់បញ្ចូលទាំងអ្នកអភិបាលសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងមូល នៅគ្រប់លំដាប់នៃប្រព័ន្ធសុខាភិបាល។ គប្បីពិចារណាលើការប្រើប្រាស់យន្តការសមាហរណកម្មសម្រាប់ការបណ្តុះបណ្តាលដូចជាការបណ្តុះបណ្តាលរួមបញ្ចូលគ្នា និងប្រើប្រាស់យន្តការដែលមានស្រាប់ ដើម្បីទាញយកបាននូវផលប្រយោជន៍ជាអតិបរមាពីធនធានដែលមាន ។

- វិធីសាស្ត្រនៃការបណ្តុះបណ្តាល៖ បណ្តុះបណ្តាលគ្រូបង្គោល និងបណ្តុះបណ្តាលបន្តដោយគ្រូបង្គោល។
- ការបណ្តុះបណ្តាលត្រូវប្រើប្រាស់កម្មវិធីបង្រៀន/ពិធីសារ/គោលការណ៍ណែនាំ ដែលរៀបចំដោយក្រសួងសុខាភិបាល កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងអនុគណៈកម្មការចំពោះកិច្ចនិមួយៗ។ ការរៀបចំកម្មវិធី ឬនិយាមនៃបណ្តុះបណ្តាលមិនគ្រាន់តែផ្តោតលើវ៉ាក់សាំងកូវីដ-១៩ប៉ុណ្ណោះទេ គប្បីឆក់យកឱកាសនេះដើម្បីពង្រឹងសមត្ថភាព យន្តការ ឬប្រព័ន្ធជាតិផ្តល់ថ្នាំបង្ការដែលបានដំណើរការជាង ៣ ទសវត្សរ៍មកហើយ។
- ចំនួនសិក្ខាកាម និងទីតាំងបណ្តុះបណ្តាល៖ គប្បីពិចារណាអំពីលទ្ធភាពបណ្តុះបណ្តាលជាក្រុមតូចៗ ឬពីចម្ងាយ។ សិក្ខាកាម និងគ្រូបណ្តុះបណ្តាលត្រូវមានចំនួនសមស្របតាមសមាមាត្រណាមួយ ដើម្បីធានាគុណភាពនិងលទ្ធផលនៃការបណ្តុះបណ្តាល និងការអនុវត្តបានល្អនូវវិធានការសុខាភិបាលបង្ការការចម្លងជំងឺកូវីដ-១៩។
- រយៈពេលបណ្តុះបណ្តាល៖ គប្បីមានរយៈពេល ១-២ ថ្ងៃ យោងតាមប្រធានបទនៃការបណ្តុះបណ្តាល។

## 4.3 បណ្តុះបណ្តាលបំប៉នផ្នែកគ្លីនិក ស្តីពីការគ្រប់គ្រងផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្តល់ចំណេះដឹងបន្ថែមដល់ក្រុមគ្រូពេទ្យក្នុងក្រុមការងារចាក់វ៉ាក់សាំងពីរបៀបគ្រប់គ្រងផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ ដែលអាចកើតមានជាយថាហេតុ ដោយប្រើប្រាស់ «ពិធីសារគ្លីនិក» ខ្លីៗ និងត្រៀមឃីតឱសថបរិក្ខារដែលត្រូវការសម្រាប់ការសង្គ្រោះបន្ទាន់។

## 4.4 ត្រួតពិនិត្យតាមដាន និងអភិបាលការប្រតិបត្តិគោលការណ៍ណែនាំឬពិធីសារនៃការងារចាក់វ៉ាក់សាំង

អនុគណៈកម្មការចំពោះកិច្ច និមួយៗ នៃគ.វ.ក ១៩ និង អនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ គប្បីចុះពិនិត្យតាមដាន និងអភិបាលនៅតាមទីតាំងចាក់វ៉ាក់សាំង ដើម្បីធានាថាការចាក់វ៉ាក់សាំងកូវីដ-១៩ អនុលោមទៅតាមពិធីសារបច្ចេកទេស ដូចជាពិនិត្យបច្ចេកទេសនៃការចាក់វ៉ាក់សាំង ការគ្រប់គ្រងវ៉ាក់សាំង ប្រព័ន្ធត្រជាក់ ការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងជាដើម។ ក្រុមចុះពិនិត្យតាមដាន ឬក្រុមចុះអភិបាលគប្បីមានសមាសភាពចម្រុះ និងមានចរិតលក្ខណៈគាំទ្រ។

# 5 ការគ្រប់គ្រងវ៉ាក់សាំង និងគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩

ប្រទេសកម្ពុជាមានប្រព័ន្ធផ្គត់ផ្គង់ និងយន្តការគ្រប់គ្រងវ៉ាក់សាំងដំណើរការបានល្អ។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងមូលដ្ឋានសុខាភិបាលគ្រប់លំដាប់ក្នុងប្រព័ន្ធសុខាភិបាល មានបទពិសោធន៍ក្នុងការផ្តល់ថ្នាំបង្ការជាប្រចាំផង និងការបញ្ចូលវ៉ាក់សាំងប្រភេទថ្មីៗ ជាច្រើនលើកផង នៅក្នុងទសវត្សរ៍កន្លងមក។ សមត្ថភាពស្តុកវ៉ាក់សាំង និងសមត្ថភាពបុគ្គលិកគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ និងថែរក្សាវ៉ាក់សាំង នៅទូទាំងប្រទេសត្រូវបានបង្កើនឡើងជាលំដាប់។

ការធានាបាននូវសុវត្ថិភាព និងប្រសិទ្ធភាពវ៉ាក់សាំង និងដំណើរការល្អនៃប្រព័ន្ធផ្គត់ផ្គង់វ៉ាក់សាំងនិងសម្ភារៈបរិក្ខារ គឺជាឆ្អឹងខ្នងនៃយុទ្ធនាចាក់វ៉ាក់សាំងកូវីដ-១៩ មានន័យថាដំណើរការចាក់វ៉ាក់សាំងអាចប្រព្រឹត្តទៅបានទាន់ពេលវេលាតាមកាលវិភាគដែលបានគ្រោងទុក និងការរក្សាបរិស្ថានអនាម័យល្អ ក្នុងបង្ការការឆ្លងរោគ តាមរយៈការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំង បានត្រឹមត្រូវ ដូចជា ម្ជុល សេរ៉ាំង ជាដើម។

អន្តរាគមន៍ក្នុងការគ្រប់គ្រងវ៉ាក់សាំង និងការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ ផ្តោតលើសកម្មភាពចម្បងដូចខាងក្រោម៖

- ការងារគ្រប់គ្រង និងបែងចែកវ៉ាក់សាំងនិងសម្ភារៈបរិក្ខារ
- ការគ្រប់គ្រងប្រព័ន្ធត្រជាក់ដើម្បីថែរក្សាសុវត្ថិភាព និងប្រសិទ្ធភាពវ៉ាក់សាំង
- ការគ្រប់គ្រងបញ្ជីសារពើភណ្ឌវ៉ាក់សាំង
- ការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំង

## 5.1 លើកកម្ពស់ការងារគ្រប់គ្រង និងបែងចែក និងផ្គត់ផ្គង់វ៉ាក់សាំង/សម្ភារៈបរិក្ខារ

- ការទិញវ៉ាក់សាំងកូវីដ-១៩ ស្ថិតនៅក្នុងក្របខណ្ឌសមត្ថកិច្ចនៃក្រុមការងារអន្តរក្រសួងទទួលបន្ទុកការចរចា និងពិគ្រោះយោបល់ទិញវ៉ាក់សាំងកូវីដ-១៩ ។

ដើម្បីសម្រេចគោលដៅនៃការគ្របដណ្តប់ការចាក់វ៉ាក់សាំងកូវីដ-១៩ លើប្រជាពលរដ្ឋគោលដៅ១០លាននាក់ ការប៉ាន់ស្មានបានអំពីចំនួនវ៉ាក់សាំងដែលត្រូវការគឺអាស្រ័យលើប្រភេទវ៉ាក់សាំងកូវីដ-១៩ដែលត្រូវចាក់២ ដូស លើមនុស្សម្នាក់ ឬ ចាក់តែ ១ដូស លើមនុស្សម្នាក់ (ដូចជាវ៉ាក់សាំង Johnson & Johnson ជាដើម)។

- រៀបចំផែនការបែកចែកវ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស

ក្រសួងសុខាភិបាល/គ.វ.ក-១៩ (អនុគណៈកម្មការចំពោះកិច្ចគ្រប់គ្រងវ៉ាក់សាំងកូវីដ-១៩) និងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ មានភារកិច្ចរៀបចំបញ្ជីបែងចែក និងផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ ដល់មូលដ្ឋានសុខាភិបាលទូទាំងប្រទេស។ ការបែងចែកវ៉ាក់សាំង ត្រូវបានធ្វើឡើងដោយឈរលើគោលការណ៍៖

- ចំនួនវ៉ាក់សាំងដែលមាន
- ក្រុមប្រជាពលរដ្ឋគោលដៅអាទិភាព
- តំបន់ដែលមានហានិភ័យនៃចម្លងជំងឺកូវីដ-១៩ ខ្ពស់
- សមត្ថភាពនៃការចាក់វ៉ាក់សាំងនៅតាមមូលដ្ឋានសុខាភិបាលគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល

អនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត ត្រូវរៀបចំផែនការបែងចែក និងផ្គត់ផ្គង់វ៉ាក់សាំងដែលបានទទួលពីឃ្លាំងឱសថកណ្តាល ទៅកាន់មូលដ្ឋានសុខាភិបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- បែងចែកនិងផ្គត់ផ្គង់ ទៅតាមផែនការបែងចែកវ៉ាក់សាំងកូវីដ-១៩

អនុគណកម្មការចំពោះកិច្ចគ្រប់គ្រងវ៉ាក់សាំងជំងឺកូវីដ-១៩ នៃគ.វ.ក-១៩ ទទួលខុសត្រូវក្នុងការគ្រប់គ្រងវ៉ាក់សាំងកូវីដ-១៩៖ ទទួលនៅអាកាសយានដ្ឋានអន្តរជាតិ និងដឹកជញ្ជូនទៅរក្សាទុកនៅឃ្លាំងឱសថកណ្តាលរបស់ក្រសួងសុខាភិបាល និងធ្វើការបែងចែក ហើយដឹកជញ្ជូនទៅឃ្លាំងស្តុកវ៉ាក់សាំងនៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

មន្ត្រីគ្រប់គ្រងឃ្លាំងឱសថកណ្តាលមានភារកិច្ចគ្រប់គ្រងស្តុក ប្រព័ន្ធរក្សាវ៉ាក់សាំង និងដឹកជញ្ជូនវ៉ាក់សាំង និងសម្ភារៈបរិក្ខារ ពីឃ្លាំងឱសថកណ្តាលឃ្លាំងស្តុកវ៉ាក់សាំងនៅរាជធានី-ខេត្តទូទាំងប្រទេស។ ក្នុងករណីបន្ទាន់មន្ទីរសុខាភិបាលរាជធានី-ខេត្ត អាចមកទទួលវ៉ាក់សាំងនិងសម្ភារៈបរិក្ខារពីឃ្លាំងឱសថកណ្តាលដោយផ្ទាល់។

- ឃ្លាំងឱសថកណ្តាលផ្គត់ផ្គង់/ដឹកជញ្ជូនវ៉ាក់សាំងដល់មន្ទីរសុខាភិបាលរាជធានី-ខេត្ត តាម«ពិធីសារនៃការបែងចែកវ៉ាក់សាំង និងសម្ភារៈក្នុងរយៈពេល៧ថ្ងៃ»។ វ៉ាក់សាំងអាចត្រូវបានដឹកជញ្ជូនទៅកាន់រាជធានី-ខេត្តនៅក្នុងថ្ងៃតែមួយ។
- ការផ្គត់ផ្គង់វ៉ាក់សាំងដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាព និងមណ្ឌលចាក់វ៉ាក់សាំង ក្នុងតំបន់ទទួលខុសត្រូវរបស់ស្រុកប្រតិបត្តិ គឺជាសមត្ថកិច្ចរបស់មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ។

## 5.2 ពង្រឹងការគ្រប់គ្រងប្រព័ន្ធត្រជាក់ថែរក្សាសុវត្ថិភាពនិងប្រសិទ្ធភាពវ៉ាក់សាំង

ការស្តុកវ៉ាក់សាំង ការដឹកជញ្ជូនវ៉ាក់សាំង និងការរក្សាប្រព័ន្ធត្រជាក់ ត្រូវអនុលោមតាមពិធីសារដែលបានកំណត់ ដើម្បីរក្សាគុណភាព និងប្រសិទ្ធភាពវ៉ាក់សាំងបានល្អ ចៀសវាងការខូចខាត។

## 5.3 គ្រប់គ្រងបញ្ជីសារពើភណ្ឌវ៉ាក់សាំង

ឃ្លាំងឱសថកណ្តាល មន្ទីរពេទ្យជាតិ មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិត្រូវគ្រប់គ្រង ធ្វើបច្ចុប្បន្នកម្មបញ្ជីសារពើភណ្ឌវ៉ាក់សាំង និងរាយការណ៍ លើមូលដ្ឋានទៀងទាត់ ទៅតាមគោលការណ៍ណែនាំ និងតាមប្រព័ន្ធដែលមានស្រាប់។

## 5.4 គ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងដើម្បីបង្ការការឆ្លងរោគ សុវត្ថិភាពនិងរក្សាអនាម័យបរិស្ថានល្អ

សំណល់ជាច្រើនត្រូវបានបន្សល់ទុកក្រោយពីបញ្ចប់ការចាក់វ៉ាក់សាំងម្តងៗ ដែលសំណល់ទាំងនោះមានគ្រោះថ្នាក់ច្រើន។ ដូច្នេះមូលដ្ឋានសុខាភិបាល និងមណ្ឌលចាក់វ៉ាក់សាំង ត្រូវគ្រប់គ្រងសំណល់ទាំងនោះ ទៅតាម «គោលការណ៍ណែនាំជាតិស្តីពីសុវត្ថិភាពចាក់ថ្នាំបង្ការ និងការគ្រប់គ្រងសំណល់និងប្រព័ន្ធបោះចោលសំរាមសម្រាប់កម្មវិធីចាក់ថ្នាំបង្ការ» នៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងសេវាផ្តល់ថ្នាំបង្ការតាមភូមិ ដើម្បីសុវត្ថិភាព និងរក្សាអនាម័យបរិស្ថានល្អ ។

ប្រធានមន្ទីរពេទ្យបង្អែកគ្រប់កម្រិត ប្រធានមណ្ឌលសុខភាព និងមន្ត្រីទទួលខុសត្រូវមណ្ឌលចាក់វ៉ាក់សាំងត្រូវពិនិត្យ និងចាត់ចែងលើការប្រមូល និងទុកដាក់កាកសំណល់ក្រោយការចាក់វ៉ាក់សាំង តាមវិធានខាងក្រោម៖

- ប្រមូលប្រអប់សុវត្ថិភាពដែលប្រើរួចទាំងអស់ រួចដឹកទៅកន្លែងកាន់កន្លែងដុត តាមការកំណត់
- ដុតបំផ្លាញប្រអប់សុវត្ថិភាពឱ្យបានឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីបញ្ចប់ការចាក់ម្តងៗ
- ត្រួតពិនិត្យការប្រមូល វេចខ្ចប់ និងការដុតបំផ្លាញ ដោយអ្នកអភិបាលតាមមូលដ្ឋានសុខាភិបាល

អនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ត្រូវមានមធ្យោបាយ និងធនធានចាំបាច់គ្រប់គ្រាន់ ដើម្បីប្រមូល ទុកដាក់ និងកំទេចសំណល់ក្រោយការចាក់វ៉ាក់សាំង ជៀសវាងការចម្លងមេរោគបណ្តាលមកពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩។

## គំនូសបំព្រួញបង្ហាញពីគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់វ៉ាក់សាំង និងគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំង



# 6 ការប្រាស្រ័យទាក់ទងនិងការចូលរួមរបស់សហគមន៍

ក្នុងយុទ្ធនាការនៃការចាក់វ៉ាក់សាំងកូវីដ-១៩ រាជរដ្ឋាភិបាលនឹងមានវ៉ាក់សាំងជាច្រើនប្រភេទសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋគោលដៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលវ៉ាក់សាំងទាំងនោះត្រូវបានផលិតឡើងលើមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាផ្សេងៗគ្នា ហើយប្រសិទ្ធភាព សុវត្ថិភាព និងផលរំខានក្រោយការចាក់វ៉ាក់សាំង នៃវ៉ាក់សាំងទាំងនោះក៏មានកម្រិតខុសៗគ្នាដែរ។ ដូច្នេះការប្រាស្រ័យទាក់ទង គឺជាអន្តរាគមន៍ដ៏សំខាន់មួយ ដើម្បីកសាងទំនុករបស់សាធារណជន ជាពិសេសក្រុមប្រជាពលរដ្ឋគោលដៅ ឱ្យចូលរួមដោយស្ម័គ្រចិត្តទទួលយកការចាក់វ៉ាក់សាំង។ ជាមួយគ្នានេះលទ្ធផលនៃការពិនិត្យតាមដានជាប្រចាំ អំពីការយល់ឃើញរបស់សាធារណជនអំពីការចាក់វ៉ាក់សាំង គឺជាតឹកតាង ដ៏សំខាន់សម្រាប់ការរៀបចំព័ត៌មាន ឬសារ ឱ្យបានសមស្រប ឆ្លើយតបទៅនឹងការយល់ឃើញរបស់ប្រជាពលរដ្ឋ ពិសេសដោះស្រាយបញ្ហា ឬឧបសគ្គ នានា ដែលប៉ះពាល់ដល់ការមកទទួលចាក់វ៉ាក់សាំងរបស់ប្រជាពលរដ្ឋ។ អន្តរាគមន៍នៃការប្រាស្រ័យទំនាក់ទំនង សុវត្ថិភាពនៃការចាក់វ៉ាក់សាំង និងការចូលរួមរបស់សហគមន៍ ផ្តោតជាចម្បងដល់ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋគោលដៅ ឱ្យព្រមទទួលយកការចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត៖

- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋឱ្យចូលរួមចាក់វ៉ាក់សាំងកូវីដ-១៩
- លើកកម្ពស់ការយល់ដឹងរបស់គ្រូពេទ្យបុគ្គលិកសុខាភិបាលអំពីអត្ថប្រយោជន៍ សុវត្ថិភាព និងផលរំខាននៃវ៉ាក់សាំងកូវីដ-១៩
- ដំណើរការយន្តការគ្រប់គ្រងផលរំខានក្រោយពីចាក់វ៉ាក់សាំងកូវីដ-១៩
- ពង្រឹងយន្តការដែលមានស្រាប់នៅក្នុងសហគមន៍ដើម្បីគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

**អន្តរាគមន៍ទាក់ទងនឹងការព្រមទទួលចាក់វ៉ាក់សាំងកូវីដ-១៩**



| | ការយល់ដឹងពីវ៉ាក់សាំង |
|---|---|
| ការបដិសេធ | **បុគ្គលបដិសេធការចាក់វ៉ាក់សាំងកូវីដ ១៩ ដោយសារកង្វល់នៃសុវត្ថិភាព៖** ត្រូវប្រើប្រាស់បទពិសោធន៍ ការយល់ដឹង និងគុណតម្លៃដើម្បីផ្លាស់ប្តូរការយល់ឃើញនេះ។ |
| ភាពស្ទាក់ស្ទើរ | **បុគ្គលមានភាពស្ទាក់ស្ទើរក្នុងការទទួលការចាក់វ៉ាក់សាំង ដោយសារជាជំងឺថ្មី វ៉ាក់សាំងក៏ថ្មី និងមានភាពមិនប្រាកដប្រជាអំពីប្រសិទ្ធភាពនៃវ៉ាក់សាំងកូវីដ ១៩៖** ភាពស្ទាក់ស្ទើរនេះអាចផ្លាស់ប្តូរបានតាមការប្រាស្រ័យទាក់ទងជាមួយអ្នកថែទាំសុខភាពដែលគួរឱ្យទុកចិត្ត |
| ការទទួលយក | **បុគ្គលទទួលយកការចាក់វ៉ាក់សាំង៖** អាស្រ័យលើភាពងាយរ ឥទ្ធិពលនៃសង្គម និងក្រុមវិជ្ជាជីវៈ និងលទ្ធភាពនៃការទទួលយកដោយមិនមានឧបសគ្គ និងភាពមានវ៉ាក់សាំងកូវីដ ១៩ ដើម្បីផ្តល់ឱ្យទាន់ពេលវេលា។ |
| សេចក្តីត្រូវការ | **បុគ្គលត្រូវការវ៉ាក់សាំងកូវីដ ១៩៖** សេចក្តីត្រូវការខ្ពស់ បើសិនជាការផ្គត់ផ្គង់ទាបអាចនាំឱ្យមានបញ្ហានៃការធ្លាក់ទំនុកចិត្តលើការចាក់វ៉ាក់សាំង។ |
| ការគាំទ្រ/គស្ស៊ីមតិ | **បុគ្គលខ្លះបានមានបទពិសោធន៍ហើយក៏គាំទ្រដល់ការចាក់វ៉ាក់សាំងកូវីដ ១៩៖** ការគាំទ្រនេះជាគន្លឹះនៃការប្រាស្រ័យទាក់ទងនៃសុវត្ថិភាព និងការផ្លាស់ប្តូរព័ត៌មាន |

## 6.1 លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋចូលរួមចាក់វ៉ាក់សាំងកូវីដ-១៩

ផ្តល់ព័ត៌មាន ឬសារត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេលវេលា អំពីអត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ប្រសិទ្ធភាព សុវត្ថិភាព និងផលរំខានក្រោយការចាក់វ៉ាក់សាំងដែលអាចកើតមានជាយថាហេតុ និងវិធីដើម្បីទទួលបានការចាក់វ៉ាក់សាំង ឱ្យបានទូលំទូលាយដល់សាធារណៈជន គ្រូពេទ្យបុគ្គលិក និងភាគីពាក់ព័ន្ធផ្សេងទៀតដែលចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំង។ ការផ្សព្វផ្សាយព័ត៌មាន ឬសារ ត្រូវប្រើប្រាស់យន្តការនានាដែលមានប្រសិទ្ធភាព ដែលសាធារណៈជនភាគច្រើនអាចទទួលបានទាន់ពេលវេលា។ ការលុបបំបាត់ព័ត៌មានក្លែងក្លាយ ប្រឌិត និងបំភិតបំភ័យទាក់ទងនឹងការចាក់វ៉ាក់សាំងឱ្យបានទាន់ពេលវេលា។ តាមដានលទ្ធផលនៃការប្រាស្រ័យទាក់ទង ចែករំលែកចំណេះដឹង និងបទពិសោធន៍ ជាមួយសាធារណជន ដើម្បីធានាថាកង្វល់នៃសុវត្ថិភាពវ៉ាក់សាំងកូវីដ-១៩ អាចកំណត់បាន និងស្វែងរកមូលហេតុឱ្យទាន់ពេលវេលា និងមានវិធានការឆ្លើយតបជាបន្ទាន់។

- រៀបចំ ផលិត និងចែកចាយសំភារៈ ផ្សព្វផ្សាយអប់រំ សម្រាប់ការងារចាក់វ៉ាក់សាំងកូវីដ-១៩

អនុគណៈកម្មការសុវត្ថិភាព និងការប្រាស្រ័យទាក់ទងហានិភ័យ ត្រូវរៀបចំ ផលិតនិងចែកចាយសំភារៈផ្សព្វផ្សាយអប់រំ សម្រាប់ការងារចាក់វ៉ាក់សាំងកូវីដ-១៩ ដើម្បីប្រើប្រាស់នៅតាមបណ្តាក្រសួង-ស្ថាប័ន អង្គភាពដោយរាប់បញ្ចូលទាំងវិស័យឯកជន និងសហគមន៍ទូទាំងប្រទេស។ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត អង្គភាពពាក់ព័ន្ធនានា អាចចូលរួមផលិតបន្តសំភារៈផ្សព្វផ្សាយអប់រំ ទាំងនោះ និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមគ្រប់មធ្យោបាយដែលមាន ដូចជា វិទ្យុ ទូរទស្សន៍ សារព័ត៌មាន បណ្តាញទំនាក់ទំនងសង្គមនានា។

- ដំណើរការប្រព័ន្ធឆ្លើយតប ( ទំនាក់ទំនង Hotline ) នៅតាមរាជធានី-ខេត្ត ដើម្បីបង្កើនការយល់ដឹង និងការទុកចិត្តលើវ៉ាក់សាំងកូវីដ-១៩

អនុគណៈកម្មការសុវត្ថិភាព និងការប្រាស្រ័យទាក់ទងហានិភ័យ នៃ គ.វ.ក-១៩ និងអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ រដ្ឋបាលរាជធានី-ខេត្ត ត្រូវបង្កើតប្រព័ន្ធ HOTLINE ឬប្រើប្រាស់ប្រព័ន្ធ ១១៥ បច្ចុប្បន្ន ដោយមានចាត់តាំងមន្ត្រីដែលបានទទួលការបណ្តុះបណ្តាល ឱ្យទទួលខុសត្រូវលើប្រតិបត្តិការប្រព័ន្ធនេះ។ ប្រព័ន្ធ HOTLINE នេះមានមុខងារផ្តល់ការប្រឹក្សាយោបល់ ឆ្លើយតបរាល់ចំងល់នានារបស់ប្រជាពលរដ្ឋទាក់ទងនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ និងទទួលព័ត៌មានស្តីពីករណីនៃផលរំខានក្រោយពីការចាក់វ៉ាក់សាំងដែលអាចកើតមានជាយថាហេតុ ។

- គ្រប់គ្រង ត្រួតពិនិត្យ និងតាមដានប្រព័ន្ធផ្សព្វផ្សាយ ដែលអាចជះផលអវិជ្ជមានដល់ការយល់ដឹងរបស់ប្រជាពលរដ្ឋលើការចាក់វ៉ាក់សាំងកូវីដ-១៩

អនុគណៈកម្មការចំពោះកិច្ចសុវត្ថិភាពវ៉ាក់សាំងនិងការប្រាស្រ័យទាក់ទងហានិភ័យ និងអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត មន្ទីរសុខាភិបាលរាជធានី-ខេត្ត ការិយាល័យស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព ត្រូវមានក្រុមសម្រាប់តាមដានប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញសង្គម ដែលផ្តល់ព័ត៌មានទាក់ទងនឹងការចាក់វ៉ាក់សាំង ដែលធ្វើឱ្យប្រជាពលរដ្ឋមានការភ័ន្តច្រឡំ ភ័យខ្លាចក្នុងការទទួលចាក់វ៉ាក់សាំង និងធ្វើការឆ្លើយតបលុបបំបាត់ព័ត៌មានក្លែងក្លាយនេះ ឱ្យបានទាន់ពេលវេលា។

- តាមដាននិងវាយតម្លៃការយល់ដឹងរបស់ប្រជាពលរដ្ឋលើការវ៉ាក់សាំងកូវីដ ១៩

អនុគណៈកម្មការចំពោះកិច្ចសុវត្ថិភាពនិងការប្រាស្រ័យទាក់ទងនៃហានិភ័យ ត្រូវរៀបចំឱ្យមានឧបករណ៍តាមដាន ដូចជាកម្រងសំណួរសម្រាប់ប្រើប្រាស់ក្នុងការតាមដានជាប្រចាំ និងគប្បីរៀបចំធ្វើការអង្កេតស្តីពី«ឥរិយាបទការយល់ឃើញ និងការព្រមទទួលចាក់វ៉ាក់សាំង» របស់ប្រជាពលរដ្ឋ ដើម្បីជាជំនួយដល់ការដោះស្រាយការងារប្រឈម ឬឧបសគ្គក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩ ដែលប្រជាពលរដ្ឋអាចជួបប្រទះ ។

## 6.2 ដាក់ឱ្យដំណើរការយន្តគ្រប់គ្រងផលរំខានក្រោយពីចាក់វ៉ាក់សាំងកូវីដ-១៩ និងក្រុមការងារស្រាវជ្រាវនៃផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

អនុគណៈកម្មការចំពោះកិច្ចសុវត្ថិភាពវ៉ាក់សាំងកូវីដ-១៩និងការប្រាស្រ័យទាក់ទងនៃហានិភ័យ កម្មវិធីជាតិផ្តល់ថ្នាំបង្ការ មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងការិយាល័យសុខាភិបាលស្រុកនិមួយៗ ត្រូវរៀបចំនិងដាក់ឱ្យដំណើរការយន្តការតាមដានផលរំខានក្រោយការចាក់វ៉ាក់សាំង ដោយប្រើប្រាស់ និងពង្រឹងយន្តការដែលមានស្រាប់នៅគ្រប់លំដាប់ក្នុងប្រព័ន្ធសុខាភិបាល ដែលបានដាក់ឱ្យដំណើរការក្នុងក្របខណ្ឌទូលាយនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ចៀសវាងការបង្កើតយន្តការត្រួតជាន់គ្នា។

ក្រុមការងារស្រាវជ្រាវផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ១៩ នៅគ្រប់លំដាប់ថ្នាក់មានភារកិច្ចពិនិត្យតាមករណីរាយការណ៍ពីផលរំខានក្រោយការចាក់វ៉ាក់សាំង និងចុះធ្វើការស្រាវជ្រាវរកមូលហេតុ រាយការណ៍ និងស្នើសុំយោបល់ពីអនុគណៈកម្មការចំពោះកិច្ចសុវត្ថិភាពវ៉ាក់សាំងនិងការប្រាស្រ័យទាក់ទងនៃហានិភ័យ និងអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងនៃរាជធានី-ខេត្ត។ របាយការណ៍ស្តីពីករណីនៃផលរំខានក្រោយការចាក់វ៉ាក់សាំង ត្រូវធ្វើការវិភាគអំពីមូលហេតុនៃផលរំខានដែលបានរាយការណ៍ ចងក្រងរបាយការណ៍ និងប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាដែលបានរកឃើញ។

## 6.3 លើកកម្ពស់ការយល់ដឹងរបស់គ្រូពេទ្យនិងបុគ្គលិកសុខាភិបាលអំពីអត្ថប្រយោជន៍ សុវត្ថិភាព និងផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩

ក្រុមការងារចាក់វ៉ាក់សាំង គ្រូពេទ្យបុគ្គលិកសុខាភិបាល ត្រូវមានការយល់ដឹងច្បាស់លាស់អំពីសុវត្ថិភាព ប្រសិទ្ធភាពនៃវ៉ាក់សាំង និងផលរំខានក្រោយការចាក់វ៉ាក់សាំង ដើម្បីផ្តល់ព័ត៌មាន និងការណែនាំចាំបាច់ផ្សេងៗ ដល់ប្រជាពលរដ្ឋគោលដៅនៃការចាក់វ៉ាក់សាំង។ ដូច្នេះការបណ្តុះបណ្តាលអំពីចំណេះដឹងទាំងនេះ គប្បីត្រូវបានរៀបចំ ប្រសិនបើត្រូវការចាំបាច់។ គ្រូពេទ្យ និងបុគ្គលិកសុខាភិបាល អាចជាអ្នកដែលមានឥទ្ធិពលជាងគេ ក្នុងការណែនាំអប់រំ ប្រជាពលរដ្ឋឱ្យយល់ព្រមទទួលយកការចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត ។

## 6.4 ពង្រឹងយន្តការដែលមានស្រាប់នៅក្នុងសហគមន៍ ដើម្បីគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

ចលនា និងលើកទឹកចិត្ត តាមមធ្យោបាយដែលមាន ដល់បណ្តាញក្រុមការងារនានាតាមសហគមន៍ ដូចជាក្រុមទ្រទង់សុខភាពភូមិ គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមការងារកាកបាទក្រហម អ្នកស្ម័គ្រចិត្ត រដ្ឋបាលមូលដ្ឋាន និងអង្គការសង្គមស៊ីវិល ឱ្យចូលរួមក្នុងយុទ្ធនាចាក់វ៉ាក់សាំង ជាពិសេស ការជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យព្រមទទួលយកការវ៉ាក់សាំងកូវីដ-១៩។

# 7 ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ មានបំណងពិនិត្យមើលជាប្រចាំវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ខណៈដែលការវាយតម្លៃនឹងវាស់វែងមើលការសម្រេចលទ្ធផលចុងក្រោយនៃការចាក់វ៉ាក់សាំង ពោលគឺ អត្រាគ្របដណ្តប់ការនៃការចាក់វ៉ាក់សាំងលើប្រជាពលរដ្ឋគោលដៅ។ ផែនការមេសម្រាប់ការចាក់វ៉ាក់សាំងកូវីដ-១៩ បានកំណត់អត្រាគ្របដណ្តប់ការចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបាន ៩៥% លើក្រុមគោលដៅអាទិភាព ។ ការកំណត់អត្តសញ្ញាណក្រុមគោលដៅអាទិភាព ដើម្បីវាស់វែងអត្រាគ្របដណ្តប់ឱ្យបានត្រឹមត្រូវ នៅក្នុងរាជធានី-ខេត្ត និងស្រុកប្រតិបត្តិនីមួយៗអាចធ្វើទៅបាន អាស្រ័យដោយមានការកត់ត្រាទិន្នន័យអ្នកចាក់វ៉ាក់សាំងបានត្រឹមត្រូវ និងគួរឱ្យទុកចិត្តបាន។

សូចនាករសម្រាប់តាមដានការចាក់វ៉ាក់សាំងកូវីដ-១៩ រួមមាន៖

- ចំនួន ឬ ភាគរយនៃប្រជាពលរដ្ឋក្រុមគោលដៅនីមួយៗ ដែលបានទទួលវ៉ាក់សាំងលើកទី១ (ដំបូង)
- ចំនួន ឬ ភាគរយនៃប្រជាពលរដ្ឋក្រុមគោលដៅនីមួយៗ ដែលបានទទួលវ៉ាក់សាំងលើកទី ២
- សមាមាត្រប្រជាពលរដ្ឋ ក្នុងក្រុមគោលដៅនីមួយៗ ដែលបានទទួលដូសលើកទី១ ប៉ុន្តែមិនបានទទួលដូសទី ២
- ចំនួន ឬ ភាគរយនៃប្រជាពលរដ្ឋក្រុមគោលដៅនីមួយៗ បានទទួលវ៉ាក់សាំងទាំងពីរដូស តាមរាជធានីខេត្ត និងតាមស្រុកប្រតិបត្តិ
- ចំនួន ឬ ភាគរយនៃស្ត្រី នៅក្នុងក្រុមគោលដៅនីមួយៗដែលបានទទួលវ៉ាក់សាំងទាំងពីរដូស

អន្តរាគមន៍នៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃផ្តោត លើសកម្មភាពចម្បងៗ ដូចខាងក្រោម៖

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យ/ព័ត៌មានទាក់ទងនឹងការងារចាក់វ៉ាក់សាំងកូវីដ១៩
- ពង្រឹងសមត្ថភាពស្ថាប័នលើការគ្រប់គ្រងទិន្នន័យ ដូចជាការប្រមូល វិភាគ បកស្រាយទិន្នន័យ រៀបចំរបាយការណ៍ និងប្រើប្រាស់របាយការណ៍
- ពង្រឹងយន្តការត្រួតពិនិត្យតាមដាន និងប្រព័ន្ធរាយការណ៍
- វាយតម្លៃការងារចាក់វ៉ាក់សាំងបង្ការក្រោយបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំង

## 7.1 អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យ/ព័ត៌មានទាក់ទងនឹងការងារចាក់វ៉ាក់សាំងកូវីដ-១៩

- បង្កើតនិងប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា/ឌីជីថល www.cambodia-vaccine.gov.kh សម្រាប់ការគ្រប់គ្រងទិន្នន័យ/ព័ត៌មានទាក់ទងការងារ ចាក់វ៉ាក់សាំងកូវីដ-១៩ និងឧបករណ៍សម្រាប់ការតាមដានត្រួតពិនិត្យ។

ប្រព័ន្ធព័ត៌មានវិទ្យានេះជាឧបករណ៍ដ៏សំខាន់ដែលជួយឱ្យការងារចាក់វ៉ាក់សាំងផង និងសកម្មភាពតាមដានត្រួតពិនិត្យផង ។ ប្រព័ន្ធនេះផ្ទុកមុខងារសំខាន់ៗ សម្រាប់៖

- ចុះបញ្ជីអ្នកស្ម័គ្រចាក់វ៉ាក់សាំងកូវីដ-១៩
- កត់ត្រាទិន្នន័យនៃការចាក់វ៉ាក់សាំង
- រំលឹកអំពីកាលបរិច្ឆេទ និងទីតាំងមកចាក់វ៉ាក់សាំងលើកទី ២
- រៀបចំរបាយការណ៍ស្ដីលទ្ធផលនៃការចាក់វ៉ាក់សាំង
- របាយការណ៍ស្ដីករណីនៃផលរំខានក្រោយការចាក់វ៉ាក់សាំង
- ផ្ដល់ព័ត៌មានចាំបាច់នានាស្ដីពីការចាក់វ៉ាក់សាំង

អនុគណៈកម្មការចំពោះកិច្ចទទួលបន្ទុកការងារតាមដានត្រួតពិនិត្យ នៃ គ.វ.ក-១៩ ទទួលបន្ទុកក្នុងការបង្កើត និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធនេះនៅក្នុងទូទាំងប្រទេស។

- រៀបចំឧបករណ៍កត់ត្រាទិន្នន័យអ្នកចាក់វ៉ាក់សាំង ក្នុងទម្រង់របាយការណ៍បំពេញដោយដៃ និងឧបករណ៍ចាំបាច់ផ្សេងទៀតសម្រាប់ការងារត្រួតពិនិត្យតាមដាន (ឧ. បញ្ជីផ្ទៀងផ្ទាត់)។

  ទម្រង់របាយការណ៍បំពេញដោយដៃកត់ត្រាទិន្នន័យអ្នកចាក់វ៉ាក់សាំង ត្រូវមានសម្រាប់ប្រើប្រាស់ នៅក្នុងករណីប្រព័ន្ធព័ត៌មានwww.cambodia-vaccine.gov.kh ឬមិនអាចប្រើប្រាស់បាន ។ ក្នុងករណីនេះ ក្រុមការងារចាក់វ៉ាក់សាំងត្រូវកត់ត្រាទិន្នន័យអ្នកចាក់វ៉ាក់សាំង ក្នុងទម្រង់របាយការណ៍បំពេញដោយដៃ បន្ទាប់មកបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ www.cambodia-vaccine.gov.kh ។

## 7.2 បង្កើនសមត្ថភាពស្ថាប័នលើការគ្រប់គ្រងទិន្នន័យ ដូចជាការប្រមូល វិភាគបកស្រាយទិន្នន័យ រៀបចំរបាយការណ៍ និងប្រើប្រាស់របាយការណ៍

- បណ្ដុះបណ្ដាលមន្ត្រីគ្រប់គ្រង និងប្រើប្រាស់ព័ត៌មានវិទ្យា ស្ដីពីការគ្រប់គ្រង ថែទាំ និងប្រើប្រាស់ប្រព័ន្ធ www.cambodia-vaccine.gov.kh ។
- បណ្ដុះបណ្ដាលដល់មន្ត្រីគ្រប់គ្រងយុទ្ធការចាក់វ៉ាក់សាំងតាមលំដាប់ថ្នាក់ ស្ដីពីការវិភាគ បកស្រាយទិន្នន័យ រៀបចំរបាយការណ៍ និងប្រើប្រាស់របាយការណ៍ ដើម្បីលើកកម្ពស់ការងារចាក់វ៉ាក់សាំង។
- អភិបាលគាំទ្រទៀងទាត់ ពិនិត្យតាមដានជាប្រចាំ និងផ្ដល់យោបល់ត្រឡប់ទាន់ពេលវេលា ដើម្បីធានាភាពពេញលេញ ភាពត្រឹមត្រូវ និងគុណភាពទិន្នន័យ ។

មន្ត្រីគ្រប់គ្រង គប្បីមានសមត្ថភាពក្នុងការវិភាគបកស្រាយ និងប្រើប្រាស់ទិន្នន័យ ឬរបាយការណ៍លទ្ធផលនៃការងារចាក់វ៉ាក់សាំង ឬរបាយការណ៍ការត្រួតពិនិត្យតាមដាន ដើម្បីលើកកម្ពស់ការងារគ្រប់គ្រង រៀបចំ និងអនុវត្តផែនការសកម្មភាព។

## 7.3 ពង្រឹងយន្តការរាយការណ៍ស្តីពីការងារចាក់វ៉ាក់សាំង លំហូររបាយការណ៍ សន្តិសុខទិន្នន័យ និងឯកជនភាព

- ដាក់ឱ្យដំណើរការយន្តការរាយការណ៍ជាប្រចាំ ស្តីពីលទ្ធផលនៃការងារចាក់វ៉ាក់សាំង ជាលក្ខណៈប្រចាំថ្ងៃ ប្រចាំសប្តាហ៍និងប្រចាំខែ តាមចរន្តរាយការណ៍ដូចបានបង្ហាញតាមគំនូសបំព្រួញខាងក្រោម៖

គំនូសបំព្រួញបង្ហាញពីចរន្តរាយការណ៍ស្តីពីការងារចាក់វ៉ាក់សាំងកូវីដ-១៩



### ក. របាយការណ៍ស្តីពីលទ្ធផលនៃការងារចាក់វ៉ាក់សាំង

- របាយការណ៍ប្រចាំថ្ងៃត្រូវបញ្ចូលទិន្នន័យឱ្យបានចប់សព្វគ្រប់ក្នុង www.cambodia-vaccine.gov.kh ចន្លោះពីម៉ោង ៥-៦ ល្ងាច ក្រោយបញ្ចប់ការចាក់វ៉ាក់សាំងប្រចាំថ្ងៃ ។
- របាយការណ៍ប្រចាំសប្តាហ៍ ត្រូវរាយការណ៍នៅថ្ងៃច័ន្ទនៃសប្តាហ៍បន្ទាប់
- របាយការណ៍ប្រចាំខែ ត្រូវរាយការណ៍នៅថ្ងៃទីមួយ នៃខែបន្ទាប់

របាយការណ៍លទ្ធផលនៃការចាក់វ៉ាក់សាំង ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ នៅតាមទីតាំងនិមួយៗ នៅទូទាំងស្រុកប្រតិបត្តិទូទាំងរាជធានី-ខេត្ត និងទូទាំងប្រទេសអាចទាញយកចេញពីប្រព័ន្ធ www.cambodia-vaccine.gov.kh ដោយស្វ័យប្រវត្តិ តាមទម្រង់របាយការណ៍ស្តង់ដារ ដែលដាក់បានបញ្ចូលនៅក្នុងប្រព័ន្ធនេះ ។ ក្នុងអន្តរកាលដែលប្រព័ន្ធនេះមិនទាន់ដំណើរពេញលេញ របាយការណ៍ត្រូវបំពេញដោយដៃ តាមទម្រង់គំរូដែលកំណត់ដោយ គ.វ.ក-១៩។

### ខ. របាយការណ៍ពីការប្រើប្រាស់វ៉ាក់សាំង និងសម្ភារៈបរិក្ខារ

ក្រុមចាក់វ៉ាក់សាំងកូវីដ-១៩ រៀបចំរបាយការណ៍ស្តីពីការផ្គត់ផ្គង់(វ៉ាក់សាំងនិងភ័ស្តុភារ) ឱ្យបានត្រឹមត្រូវប្រចាំថ្ងៃ ដោយប្រើប្រាស់ទម្រង់របាយការណ៍ និងរាយការណ៍តាមប្រព័ន្ធដែលបានកំណត់ដោយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។

- លើកកម្ពស់ការប្រើប្រាស់របាយការណ៍ និងការផ្តល់ព័ត៌មានត្រឡប់ ដើម្បីកែលម្អការងារចាក់វ៉ាក់សាំងនៅតាមលំដាប់ថ្នាក់និមួយៗ នៃប្រព័ន្ធសុខាភិបាល។

គ.វ.ក-១៩ អនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត អង្គភាពសុខាភិបាលគ្រប់ជាន់ថ្នាក់ ត្រូវពិនិត្យរបាយការណ៍នៃការងារចាក់ថ្នាំបង្ការជាទៀងទាត់ ដើម្បីតាមដានវឌ្ឍនភាពផង និងដោះស្រាយបញ្ហាជួបប្រទះផង ឱ្យបានទាន់ពេលវេលា និងផ្តល់យោបល់ណែនាំ ឬយោបល់ត្រឡប់ទៅកាន់អង្គភាពរាយការណ៍វិញ។

## 7.4 ការវាយតម្លៃនៃការបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

- រៀបចំការវាយតម្លៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ បន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ បានបញ្ចប់។

ការវាយតម្លៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវធ្វើឡើងដោយអនុគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យតាមដាននិងវាយតម្លៃ ដោយសហការជាមួយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងដៃគូភាគីពាក់ព័ន្ធនានា ។ របាយការណ៍នៃការវាយតម្លៃនេះនឹងផ្តល់មេរៀន បទពិសោធន៍ ទាំងចំណុចខ្លាំង និងចំណុចខ្សោយ ព្រមទាំងកាលានុវត្តភាព សម្រាប់ពង្រឹងប្រព័ន្ធជាតិកម្មវិធីផ្តល់ថ្នាំបង្ការ និងប្រព័ន្ធសុខាភិបាលក្នុងពេលអនាគត ។

# 8 គម្រោងចំណាយ

យោងតាមផែនការសកម្មភាពនិងថវិកានៃអនុគណៈកម្មការចំពោះកិច្ចនៃគ.វ.គ-១៩ និងអនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត គម្រោងចំណាយសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស សម្រាប់រយៈពេល ៩ខែ (មេសា-ធ្នូ ឆ្នាំ២០២១) មានទឹកប្រាក់សរុប ៨៣.៦២៥.៧៩២.០០០ រៀល (ប៉ែតសិបបីប៊ីលាន ប្រាំមួយរយម្ភៃប្រាំលាន ប្រាំពីររយកៅសិបពីរពាន់រៀលគត់)ឬស្មើនឹង ២០.៥៩៧.៤៨៦ ដុល្លារអាមេរិក (ម្ភៃលាន ប្រាំរយកៅសិបប្រាំពាន់ បួនរយប៉ែតសិបប្រាំមួយដុល្លារអាមេរិក) ដោយមិនបញ្ចូលតម្លៃវ៉ាក់សាំងកូវីដ-១៩) សម្រាប់ការអនុវត្តសកម្មភាពរបស់អនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត និងអនុគណៈកម្មការចំពោះកិច្ចនៃគ.វ.ក-១៩។អនុគណៈកម្មការចំពោះកិច្ចផែនការនិងថវិកានឹយកម្មនឹងពិនិត្យមើលឡើងវិញនូវផែនការសកម្មភាព និងថវិកា និងពិនិត្យលើសំណើសុំថវិកា ដើម្បីអនុវត្តផែនការសកម្មភាពរបស់អនុគណៈកម្មការចំពោះកិច្ចនីមួយៗ។

**គម្រោងចំណាយថវិកាតាមផ្នែកយុទ្ធសាស្ត្រនៃផែនការមេសម្រាប់កាចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ក្នុងក្របខណ្ឌទូទាំងប្រទេស រយៈពេល ៩ ខែ (មេសា-ធ្នូ ២០២១)**

(គិតជា ពាន់រៀល)

| បរិយាយ | សរុប |
|---|---|
| | **83,652,792** |
| 1. អភិក្រមនៃការចាក់វ៉ាក់សាំង៖កិច្ចដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ | **59,586,642** |
| 2. ការដឹកនាំ គ្រប់គ្រង ផែនការ និងការសម្របសម្រួល | **8,547,601** |
| 2.1. រៀបចំ បច្ចុប្បន្នកម្មផែនការ តាមដានត្រួតពិនិត្យការអនុវត្តផែនការ | 152,370 |
| 2.2. រៀបចំឧបករណ៍ យន្តការ ប្រព័ន្ធ សម្រាប់ដំណើរការចាក់វ៉ាក់សាំង | 4,964,039 |
| 2.3. ការសម្របសម្រួលក្នុងយុទ្ធនាការចាក់វ៉ាក់សាំង | 3,431,192 |
| 3. ធនធានមនុស្ស (បណ្ដុះបណ្ដាលបំប៉នបច្ចេកទេស) | **1,196,156** |
| 4. ការគ្រប់គ្រងវ៉ាក់សាំង និងសំណល់ក្រោយការចាក់វ៉ាក់សាំង | **4,303,288** |
| 5. ការប្រាស្រ័យទាក់ទង សុវត្ថិភាព និងការចូលរួមពីសហគមន៍ | **1,168,521** |
| 6. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការងារចាក់វ៉ាក់សាំង | **5,343,640** |
| 6.1. ដំណើរការចុះបញ្ជី និងការគ្រប់គ្រងទិន្នន័យ/ព័ត៌មាន | 2,154,664 |
| 6.2. ពង្រឹងយន្តការរាយការណ៍ពីការងារចាក់វ៉ាក់សាំង ចរន្តរបាយការណ៍ | 3,188,976 |
| 7. ចំណាយផ្សេងៗ | **3,506,944** |